ជំពូក ៥

ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និង វិធានការកាត់បន្ថយ

Potential Environmental Impacts and Mitigation Measures

Draft

ជំពូកទី ៥

ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និង វិធានការកាត់បន្ថយ

៥.១ សេចក្តីផ្តើម (Indroduction)

ការសិក្សានេះយោងតាមអនុក្រឹត្យស្តីអំពី កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលចុះហត្ថលេខាដោយ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ចូលជាធរមាននៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ។ គំរោងវិនិយោគ សាងសង់វារីអគ្គិសនីកំចាយរបស់ ក្រុមហ៊ុន SINOHYDRO Corporation Limited. បានចុះធ្វើការសិក្សា ស្រាវជ្រាវ និងរៀបចំរបាយការណ៍ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមដំបូង (IESIA) ចាប់ពីថ្ងៃទី ១៦ ខែ សីហា ដល់ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៦ ។

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមដំបូង (IESIA) នេះ គឺជាការអង្កេត សិក្សាស្រាវជ្រាវដើម្បីរក និងកំណត់ហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមក្នុងដំណាក់កាលរចនាគំរោង (Project Design) សាងសង់ (Project Construction) ប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance) ហើយនិងដំណាក់កាលបិទគំរោង (Project Closure) ។ ហេតុប៉ះពាល់បរិស្ថានទាំងនោះ ត្រូវរកវិធានការកាត់បន្ថយឱ្យដល់កំរិតអតិបរមា និងធ្វើផែនការគ្រប់គ្រង បរិស្ថាន នៃដំណាក់កាលរបស់គំរោងទាំងនោះ ដោយមានការអនុវត្តន៍ពីម្ចាស់គំរោង រួមកិច្ចសហការត្រួតពិនិត្យពីបណ្តាស្ថាប័ន ជំនាញពាក់ព័ន្ធ ដូចជា មន្ទីរបរិស្ថានខេត្តកំពត . មន្ទីរកសិកម្មខេត្តកំពត . មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ខេត្តកំពត . អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ . ដោយមានការគ្រប់គ្រងតាមខ្សែបណ្តោយពីក្រសួងបរិស្ថាន . ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។ ក្នុងដំណើរវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមដំបូងនេះ ក្រុមការងារ SAWAC បានប្រើប្រាស់ក្រដាស់ Checklist ដើម្បីកំណត់ទំហំនៃការប៉ះពាល់ រួចជ្រើសយកការវាយតំលៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានណាដែលមានកំរិត តិច មធ្យម និងខ្លាំង មកធ្វើវិធានការកាត់បន្ថយហេតុប៉ះពាល់ទាំងនេះឱ្យដល់កំរិតអប្បបរមា ។

៥.២ វិធីសាស្ត្រ (Methodology)

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមដំបូង (IESIA) នេះ គឺជាការអង្កេត សិក្សាស្រាវជ្រាវដើម្បីរក និងកំណត់ហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមក្នុងដំណាក់កាលរចនាគំរោង (Project Design) សាងសង់ (Project Construction) ប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance) ហើយនិងដំណាក់កាលបិទគំរោង (Project Closure) ។ ហេតុប៉ះពាល់បរិស្ថានទាំងនោះ ត្រូវរកវិធានការកាត់បន្ថយ និងធ្វើផែនការគ្រប់គ្រង បរិស្ថាន នៃដំណាក់កាលរបស់គំរោងទាំងនោះ ដោយមានការអនុវត្តន៍ពីម្ចាស់គំរោង រួមកិច្ចសហការត្រួតពិនិត្យពីបណ្តាស្ថាប័ន ជំនាញពាក់ព័ន្ធ ដូចជា មន្ទីរបរិស្ថានខេត្តកំពត . មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពត . មន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្តកំពត . ឧទ្យានជាតិបូកគោ . មន្ទីរទេសចរណ៍ខេត្តកំពត . ខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តកំពត .

អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ . ដោយមានការគ្រប់គ្រងតាមខ្សែបណ្តោយពីក្រសួងបរិស្ថាន . ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល . ក្រសួងធនធានទឹក និងឧតុនិយម . ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងក្រសួងទេសចរណ៍។ ក្នុងដំណើរវាយតំលៃហេតុប៉ះពាល់ បរិស្ថាន និង សង្គមដំបូងនេះ ក្រុមការងារ SAWAC បានប្រើប្រាស់តារាង Checklist សំរាប់គំរោងវារីអគ្គិសនី (គោលការណែនាំ វ.ហ.ប របស់ធនាគារអភិវឌ្ឍអាស៊ី) ដើម្បីកំណត់ទំហំនៃការប៉ះពាល់ រួចជ្រើសយកការវាយតំលៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានណាដែលមានភិតភ័យ មធ្យម និងខ្លាំង មកធ្វើវិធានការកាត់បន្ថយហេតុប៉ះពាល់ទាំងនេះអោយដល់កំរិតអប្បបរមា ។

តារាង Checklist សំរាប់គំរោងវារីអគ្គិសនី :

ក. ទីតាំងគំរោង: *តើតំបន់គំរោងនៅក្នុងឬក្បែរតំបន់បរិស្ថានសំខាន់ៗដែរទេ ?*	**មាន**	**គ្មាន**	**កត់សំគាល់**
• ទីតាំងមរតកវប្បធម៌		✓	
• តំបន់ការពារ	✓		ឧទ្យានជាតិបូកគោ
• តំបន់ជីវសើម		✓	
• កោងកាង		✓	
• មាត់ពាម (តំបន់ទឹកភ្លៀវ)	✓		ព្រៃកំពុងបាត់
• តំបន់ទ្រនាប់នៃតំបន់ការពារ	✓		ឧទ្យានជាតិបូកគោ
• តំបន់ពិសេសសំរាប់ការពារជីវចំរុះ	✓		ឧទ្យានជាតិបូកគោ
ខ. ផលប៉ះពាល់បរិស្ថានសំខាន់ៗ *តើគំរោងនឹងបង្កអោយ.....*			
• បាត់បង់សម្បត្តិអេកូឡូស៊ីដ៏មានតំលៃ ដោយសារការលិចលង់តំបន់កសិកម្ម/ព្រៃឈើ . ជំរកសត្វព្រៃ . វិខានដល់ត្រីពង/បង្កកំនើត និងឧបសគ្គដល់ផ្លូវបំលាស់ទីរបស់ត្រី ដែរទេ?	✓		លិចលង់តំបន់ព្រៃឈើ . ជំរកសត្វព្រៃមួយចំនួនក្នុងអាងទី១
• បាត់បង់វត្ថុបុរាណ . រូបសំណាកប្រវត្តិសាស្ត្រ រូបសំណាកវប្បធម៌ ដែរទេ?		✓	
• ការផ្លាស់ទី ឬ ការតាំងលំនៅឡើងវិញ របស់ ប្រជាជន ដោយឥតចេតនា ដែរទេ?	✓		១៥ ទៅ ៣០គ្រួសារនៅក្នុងតំបន់អាងទី២

• ការរំខាន/ឧបសគ្គ ដល់ក្រុមកុលសម្ព័ន្ធ / ប្រជាជនអន្តោគ្រាម ដែរទេ?		✓	
• ការថយចុះបរិស្ថានចេញពីកំនើនការកាន់កាប់ដីព្រៃឈើ ដីឧទ្យានជាតិ ដែរទេ?	✓		ការធ្វើចំការដំណាំ កន្លែងកំសាន្តលំនៅដ្ឋាន ។ល។
• ទំនាស់លើសិទ្ធិផ្គត់ផ្គង់ទឹក និងទំនាស់នានាទាក់ទិននឹងសង្គម ដែរទេ?	✓		មានតិចតួចលើគុណភាពប្រភពទឹករបស់រដ្ឋាករ ទឹកខេត្តកំពត (តំបន់ទឹកឈូ)
• ថយចុះទិន្នផលពីការចាប់ត្រី ដោយការពន្លិចស្ទឹងទន្លេជ្រៅវែង និងទាក់ទងនឹងការលិចលង់ប្រឡាយ ហើយជាលទ្ធផល រំខាន/ឧបសគ្គដល់ការបង្កកំនើត និងការបង្កើតកូនរបស់ត្រី ដែរទេ?	✓		មានពូជត្រីមានតំលៃមួយចំនួនរស់នៅតំបន់ស្ទឹងកំចាយ និងព្រៃកំពង់បាយ ។ តែពុំមានរបាយការណ៍បញ្ជាក់ច្បាស់លាស់ឡើយ ។
• ដំណើរវីវកសាយនៃវារីជាតិឥតប្រយោជន៍ក្នុងអាង និងនៅខ្សែទឹកខាងក្រោមធ្វើអោយថយចុះ រំហូរទឹកចេញពីទំនប់ . ប្រព័ន្ធស្រោចស្រព . នាវាចរ និងជលផល . និងបង្កើនការបាត់បង់ទឹក តាមរំហួត ដែរទេ ?	✓		អាចនឹងមានវារីជាតិឥតប្រយោជន៍ក្នុងអាងទីមួយ នៅប៉ុន្មានឆ្នាំដំបូង ។
• ការស៊ីច្រោះដីបាតស្ទឹង/ទន្លេ នៅខាងក្រោមទំនប់ ដែរទេ ?	✓		អាចនឹងមាន ព្រោះតំបន់ភ្នំកំចាយជាសិលាកំទេចកំណ និងមានល្បាយដី ។
• កំនើនឧប្បត្តិហេតុនៃជំងឺកើតពីទឹក ឬ ជំងឺទាក់ទងនឹងទឹក ដែរទេ ?	✓		អាចនឹងមានក្នុងអាងទីមួយ ដោយការពុករលួយនៃរុក្ខជាតិ និងជាជំរក និងកន្លែងបង្កកំនើត របស់សត្វមូស ខ្យង់ខ្ចៅ និងសត្វល្អិតចង្រៃ មួយចំនួន ។
• ភាពហឹនអស់អុកស៊ីសែនរលាយ ដោយកំទេចពុករលួយយ៉ាងច្រើននៃរុក្ខជាតិ ត្រីងាប់ ដោយសារការថយចុះនៃអុកស៊ីសែនរលាយក្នុងទឹក . ការវីវកដាលអាល់ហ្គៀ បង្កអោយមាន អឺត្រូហ្វីខេសិន ដែរទេ ?	✓		អាចនឹងមានទូទៅក្នុងអាងទីមួយ នៅប៉ុន្មានឆ្នាំដំបូង និងនៅផ្នែកជ្រៅនៃអាង ជាវ្រៀងរហូត ។
• ថមថយគុណភាពទឹកក្នុងអាង ដែរទេ ?	✓		អាចនឹងមានទូទៅក្នុងអាងទីមួយ នៅប៉ុន្មានឆ្នាំដំបូង ។

• ថយចុះ ឬ ផ្លាស់ប្តូរជលផលនៅខាងក្រោមអាង ដោយសារ បន្ថយរំហូរ និងជំនន់អតិបរមា ព្រមទាំងប់រែបំរូលគុណភាពទឹក ដែរទេ ?	✓		អាចនឹងមាន ដោយសារសកម្មភាពគំរោង ។
• បាត់បង់ប្រភេទត្រីបំលាស់ទី ដោយសារការរារាំង បង្អាក់នៃទំនប់ទាំពីរ ដែរទេ ?	✓		យោងតាមបួង់គំរោង ពុំឃើញមានកន្លែង អោយត្រីឆ្លងកាត់ពីខ្សែទឹកក្រោមទៅ ខ្សែទឹកខាងលើឡើយ ។
• បង្កើតការរងកកដីនៅច្រកចូលអាង បង្កអោយមាន ឥទ្ធិពលទឹកហូរបញ្ចាស់ និងការលិចលង់នៅខ្សែទឹក ខាងលើ ដែរទេ ?	✓		ចំណោទភ្នំសងខាងស្ទឹងកំចាយ មានសភាពចោទខ្លាំង និងតំបន់នេះមាន ភ្លៀងធ្លាក់ខ្លាំងជារៀងរាល់ឆ្នាំ ហើយភូគភ្គសាស្ត្រតំបន់នេះជាសិលាងាយ រងនូវស់នឹកទៀតផង ។
• ការរងកកដីនៅក្នុងអាង និងការបាត់បង់សមត្ថភាព ស្តុកទឹក ដែរទេ ?	✓		ចំណោទភ្នំសងខាងស្ទឹងកំចាយ មានសភាពចោទខ្លាំង និងតំបន់នេះមាន ភ្លៀងធ្លាក់ខ្លាំងជារៀងរាល់ឆ្នាំ ហើយភូគភ្គសាស្ត្រតំបន់នេះជាសិលាងាយ រងនូវស់នឹកទៀតផង ។
• ការផ្លាស់ប្តូរគុណភាពទឹក ដោយរំហូតក្នុងអាង , សីតុណ្ហភាពទាបអំឡុងពេលរំហូរតិច , ការប្រមូល ល្បប់ក្នុងចរន្តទឹក , ភាពរលាយអុកស៊ីសែនទាប , និង ក៏រិតជាតិដែក និងម៉ង់កាណែសខ្ពស់ ដែរទេ ?	✓		អាចនឹងមាន ដោយសារសកម្មភាពគំរោង ។
• ភាពប្រៃនៃដីទំនាបលិចទឹក និងទឹកប្រៃឈ្លានពាន មាត់ពាម និងខ្សែទឹកខាងលើ ដែរទេ ?	✓		អាចនឹងមាន ដោយសាររំហូរទាបពេក ចេញពីគំរោង ។
• បន្ថយទំនាបលិចទឹកសំរាប់កសិកម្ម ដែរទេ ?		✓	
• បញ្ហាបរិស្ថានកើតមានឡើងពី គ្មានការត្រួតពិនិត្យ ជនដែលធ្វើបំលាស់ទីចូលក្នុងតំបន់ , មានផ្លូវចេញ ចូលស្រួល និងមានខ្សែបណ្តាញគ្រប់គ្រាន់ ដែរទេ ?	✓		អាចនឹងមាន ដោយសារសកម្មភាពគំរោង ធ្វើអោយតំបន់នេះមានការរីកចំរើន និងមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ។

Draft

៥.៣ ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ
Negative Environmental Impacts and Mitigation Measures

គំរោងវារីអគ្គិសនីកំចាយមានទីតាំងនៅក្នុងតំបន់ឧទ្យានជាតិបូកគោ ដែលនៅទីនោះគ្របដណ្តប់ដោយព្រៃស្រោង និងពាក់កណ្តាលស្រោងភាគច្រើន ហើយដែលជាកន្លែងរស់នៅរបស់បក្សីដូចជា ក្ងោក ចេកទុំពណិប្រាក់ ទីទុយចំព្រៃ រអាតត្នោតស្មោញ ប៉ាក់ទាវចុងខ្ពងខ្សៀវ ចេកទេសចុងខ្ពងព្រលែត មាន់ក្រិច ដែលជាបក្សីកំពុងទទួលរងនូវការគំរាមកំហែងទុទាំងពិភពលោក ។ មានបក្សី ប្រមាណ ២៤៩ប្រភេទ ថនិកសត្ត២៩ប្រភេទ ល្មូន៩ប្រភេទ និងពពួកកង្កែប១១ប្រភេទ ត្រូវបានរកឃើញនៅក្នុងឧទ្យាននេះ យោងតាមឯកសារសិក្សាឈ្មោះ A Wildlife Survey of Bokor National Park, Cambodia, May 2001 របស់ The Wildlife Conservation Society (WCS) ។ ម្យ៉ាវិញទៀតខ្សែទីកខាងក្រោមនៃគំរោងកំចាយនេះ ជាតំបន់រមណីយដ្ឋានទេសចរណ៍ " ទីកឈូ " និងតំបន់មាត់ពាម (តំបន់ទីកភ្ជៀវ) នៃព្រែកកំពង់បាយ និងចុងបច្ចប់គឺតំបន់ឆ្នេរក្នុងខេត្តកំពតដែលនៅទីនោះសំបូរទៅដោយ ស្មៅសមុទ្រ ផ្កាថ្ម មច្ឆាជាតិ ព្រៃលិចទីក និងកោងកាង ។ ជីវិត និងជីវចំរុះនៅក្នុងសមុទ្រមាន បង្គា ក្តាមគ្រប់ប្រភេទ ខ្យងគ្រប់ប្រភេទ គ្រែងគ្រប់ប្រភេទ បង្កងឆ្មា បង្កងប៉ាក កាឈីវ ត្រីតូចធំគ្រប់ប្រភេទ អណ្តើកសមុទ្រ និងជ្រូកទីក ហើយប្រភេទជីវរសក្នុងសមុទ្រកម្ពុជាដែលត្រូវការពាររួមមាន ផ្សោតសមុទ្រ ជ្រូកទីក ស្មៅសមុទ្រ និងផ្កាថ្ម ផ្ទែកលើរបាយការណ៍ស្តីពីបរិស្ថានតំបន់ឆ្នេរ-ខេត្តកំពត រៀបរៀងឡើងដោយ ក្រសួងបរិស្ថាន និងអង្គការ DANIDA . ឆ្នាំ ២០០២ ។

យោងតាមឯកសាររចនាប្លង់គំរោង និងទីតាំងភូមិសាស្ត្រតំបន់កំចាយ ឃើញថា: ទីតាំងគំរោងនឹងមានការប៉ះពាល់ដល់ឧទ្យានជាតិបូកគោ និងតំបន់មាត់ពាម (តំបន់ទីកភ្ជៀវ) នៃព្រែកកំពង់បាយ ហើយផលប៉ះពាល់អវិជ្ជមានដែលនឹងកកើតចេញពីសកម្មភាព គំរោងតាមដំណាក់កាលនិមួយៗ មានពណិនាតាមលំដាប់លំដោយខាងក្រោមនេះ ។

៥.៣.១ ដំណាក់កាលរចនាគំរោង (Project Design)

ក្នុងដំណាក់កាលនេះគំរោងពុំមានសកម្មភាពដែលបង្កអោយមានផលប៉ះពាល់ចំដុំឡើយ ។ ដំណាកកាលរចនាគំរោងគឺមានអ្នកជំនាញការតាមផ្នែកៗបច្ចេកទេស ធ្វើការសិក្សាស្រាវជ្រាវទៅតាមជំនាញបច្ចេកទេសរៀងៗខ្លួន ដើម្បីរចនាប្លង់គំរោងតាមសមាសភាពនិមួយអោយបានល្អប្រសើរ ។ ការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗដល់ធនធានបរិស្ថាន និងសង្គមរួមមានដូចតទៅ :

៥.៣.១.១ ហេតុប៉ះពាល់អវិជ្ជមានចំពោះធនធានអេកូឡូស៊ី និង វិធានការកាត់បន្ថយ

- <u>បច្ចជាតិ និងសត្វព្រៃ</u>

> *<u>ហេតុប៉ះពាល់អវិជ្ជមាន</u>*

យោងតាម ទីតាំង និងសមាសភាពរបស់គំរោងអភិវឌ្ឍន៍វារិអគ្គិសនីកំចាយអាចនឹងមានផលប៉ះពាល់ដល់សត្វព្រៃ និងមច្ឆជាតិមួយចំនួន ដូចនេះការរចនាប្លង់គំរោងត្រូវធ្វើការសិក្សាដាក់បញ្ចូលនូវដំណោះស្រាយ សមស្របសំរាប់ផ្លូវឆ្លងកាត់របស់សត្វព្រៃ សំរាប់អោយត្រីចរាចរចុះឡើងតំបន់ទំនប់បាន ។ បញ្ហាខាងនេះ អាចជះឥទ្ធិពលមិនល្អដល់គំរោងទាំងមូលនៅពេលសាងសង់ និងដំណើរការ របស់គំរោង ។

➢ *ចំណាត់ការគាត់បន្ថយ*

ក្រុមហ៊ុននឹងធ្វើការសិក្សារចនាបថ្មង់គំរោងដោយរួមបញ្ចូល នូវសំណង់សិលប្បៈការសំរាប់អោយត្រីឆ្លងកាត់បាន បើមានការស្នើសុំពីរាជ រដ្ឋាភិបាល និងអ្នកឯកទេសជលផលជាតិ និងអន្តរជាតិ ។

ក្រុមហ៊ុននឹងធ្វើការសិក្សា និងមានការសហការជាមួយតំណាងឧទ្យានជាតិបូកគោ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ រកដំណោះស្រាយសំរាប់ផ្លូវសត្វឆ្លងកាត់ តាមលទ្ធភាពដែលអាចធ្វើបាន ។

៥.៣.១.២ ហេតុប៉ះពាល់អវិជ្ជមានទំនោះបរិស្ថានសង្គម និង វិធានការគាត់បន្ថយ

- **ការរស់នៅរបស់សហគមន៍ និងការប្រើប្រាស់ដី**

➢ *ហេតុប៉ះពាល់អវិជ្ជមាន*

ដំណាក់កាលនេះតំរោងអាចនឹងបង្កផលប៉ះពាល់ដល់សតិអារម្មណ៍ ចំពោះការរស់នៅ និងរកបរចិញ្ចឹមជីវិត របស់ប្រជាពលរដ្ឋនៅតំបន់ទឹកឈូ ដែលពួកគាត់មានការព្រួយបារម្ភ និងភ័យខ្លាចក្រុមហ៊ុនទន្ទ្រានយកដី ដែលពួកគាត់ បានកាន់កាប់ស្នាក់នៅ និងធ្វើចំការដំណាំដ៏មានតំលៃខ្ពស់បង្ហូរ ដូចជាចំការធូរេន មង្ឃុត សាវម៉ាវជាដើម ហើយនិងបាត់បង់មុខរបររកស៊ីចិញ្ចឹមជីវិតលក់ដូរអាហារ ផ្លែឈើ នៅតំបន់ទេសចរណ៍ទឹកឈូនេះ ។

អាចនឹងប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋ ដែលមានរបរប្រមូលអនុផលព្រៃឈើ ដូចជាកាប់ឬស្សី បោចផ្តៅ កាប់អូស រើសផ្លែឈើ ដែលពួកគាត់មានការព្រួយបារម្ភ ខ្លាចក្រុមហ៊ុនឈប់អោយពួកគាត់ឡើងទៅកាប់ឬស្សី កាប់អូស បោចផ្តៅ/វល្ល នៅតំបន់កំចាយនេះ ។ សព្វថ្ងៃមានអ្នកប្រកបរបររកអនុផលព្រៃឈើក្នុងតំបន់ទឹកឈូនេះជាង ២០០នាក់ ដែលពួកគាត់មកពីឃុំម៉ាក់ប្រាង្គ ឃុំកំពុងត្រែង ស្រុកកំពត . ឃុំអណ្តូងខ្មែរ ឃុំអណ្តូងប្រេង ស្រុកកំពង់បាយ និងមួយចំនួនតូចមកពីស្រុកកំពង់ត្រាច យោងតាមការផ្តល់ពត៌មានពីនាយករងឧទ្យានជាតិបូកគោ និងកាសិក្សាជាក់ស្តែងរបស់ ក្រុមសិក្សា សាវ៉ាក់ ។

ម្យ៉ាងទៀតប្រជាជនទាំងបីប្រភេទខាងលើព្រួយបារម្ភខ្លាចក្រុមហ៊ុនបិទផ្លូវដែលមានស្រាប់ក្នុងតំបន់ទឹកឈូ និងកំចាយ នេះ មិនអោយចេញចូលបានដូចសព្វដង។ ព្រោះពួកគាត់ ពុំមានពត៌មានច្បាស់លាស់អំពីគំរោងវារីអគ្គិសនីកំចាយនេះ នឹងធ្វើអ្វីខ្លះនោះទេ ហើយលឺតែពីមាត់មួយទៅមាត់មួយថា ពួកគាត់នឹងបាត់បង់ទីតាង និងរបរដែលគាត់មានសព្វថ្ងៃ ដោយសារគំរោងអភិវឌ្ឍនេះ ។

➢ *ចំណាត់ការគាត់បន្ថយ*

ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងតំបន់គំរោងនូវគោលបំណងអភិវឌ្ឍន៍ និង ហេដ្ឋារចនាសម្ព័ន្ធ គំរោងនេះ អោយប្រជាជនបានជ្រាប ដូចជាជូនដំណឹងអោយបានដល់អាជ្ញាធរភូមិ ឃុំ ការលើកផ្ទាំងប៉ាន់ណូស្តីអំពីពត៌មានគំរោង និងរូបភាព គំរោងអភិវឌ្ឍន៍កំចាយនេះ ឬប្រហាក់ប្រហែលគ្នានេះ ដែលក្រុមហ៊ុនបានធ្វើកន្លងមក ។

ក្រុមហ៊ុននឹងធ្វើការជូនដំណឹងពាក់ព័ន្ធនឹងការកាន់កាប់ដីរបស់ប្រជាជនដោយ មិនធ្វើអោយប៉ះពាល់ដល់ការកាន់កាប់ដី និង ការប្រកបរបររកស៊ីរបស់ ពួកគេក្នុងតំបន់គំរោងក្នុងតំណាក់កាលរចនាបថ្ម ។

ក្រុមហ៊ុននឹងធ្វើការពិភាក្សា និងប្រឹក្សាយោបល់ពីសហគមន៍ក្នុងតំបន់នោះ អំពីការអភិវឌ្ឍន៍គំរោងនេះ និងជូនដំណឹងជាបន្តបន្ទាប់នូវតំរូវការដីសំរាប់ការសាងសង់ផ្ទះកម្មករ ការិយាល័យ រោងជាង ផ្លូវចេញចូល ព្រមទាំងពេលវេលានៃការសាងសង់សមាសភាពគំរោងនិមួយៗ ដើម្បីអោយប្រជាពលរដ្ឋក្នុងតំបន់នឹងរងផលប៉ះពាល់មានការរៀបចំដំណោះស្រាយការរស់នៅ របររកស៊ី និងកម្មសិទ្ធិដីធ្លី ផ្ទះសំបែង ។ល។

- **<u>ផលប៉ះពាល់នៃសិទ្ធិប្រើប្រាស់ទឹកស្ទឹងកំចាយ</u>**

➢ *<u>ហេតុប៉ះពាល់អវិជ្ជមាន</u>*

មានការបារម្ភពីផ្នែកផ្គត់ផ្គង់ទឹកស្អាត រដ្ឋាករទឹកក្រុងកំពត ខ្វាចមានការខ្វះប្រភពទឹក សំរាប់បូមផ្គត់ផ្គង់ទឹកក្នុងទីក្រុងកំពត និងខ្វាចគំរោងមានការបំពុលគុណភាពទឹកពេលសាងសង់ ពេលដំណើរការ ដែលមានបញ្ហាខ្លាំងដល់ការសំអាតទឹកមុននឹងចែកចាយដល់អ្នកប្រើប្រាស់ ។

➢ *<u>វិធានការគាត់បន្ថយ</u>*

ក្រុមហ៊ុននឹងធ្វើការសិក្សារចនាបថ្នង់គំរោងដែលអាចធានាការបោះទឹកមកខ្សែទឹកខាងក្រោមអោយបានគ្រប់គ្រាន់ជាពិសេសនៅរដូវប្រាំង សំរាប់តំរូវការប្រើប្រាស់របស់រដ្ឋាករទឹក សហគមន៍រស់នៅតាមដងស្ទឹងទឹកឈូ និងរក្សាអេកូឡូស៊ីរបស់ស្ទឹងនេះផង ។

រៀបចវិធីសាស្ត្រការពារ និងកាត់បន្ថយការបំពុលគុណភាពទឹកដោយសកម្មភាពគំរោងទាំងមូល ។ ក្រុមហ៊ុនត្រូវធ្វើការផ្សព្វផ្សាយរាល់ការងារដែលអាចបង្កដល់ការបំពុលគុណភាពទឹក ដល់រដ្ឋាករទឹក និង អ្នកប្រើប្រាស់ទឹកស្ទឹងទឹកឈូ ព្រែកកំពុងបាយ ទាំងអស់ជ្រាបជាពត៌មានក្នុងរយៈពេលមួយសប្តាហ៍មុនយ៉ាងតិច ។

អនុញ្ញាតិអោយ រដ្ឋាករទឹកក្រុងកំពតមានទីតាំងបូមទឹក (ស្ថានីយបូមទឹក water intake) នៅក្នុងអាងទីពីរ ។

- **<u>មហន្តរាយដល់ជីវិត និងទ្រព្យសម្បត្តិប្រជាជន</u>**

➢ *<u>ហេតុប៉ះពាល់អវិជ្ជមាន</u>*

ប្រជាជនដែលរស់នៅតាមដងស្ទឹងទឹកឈូ និងព្រែកកំចាយ ជាពិសេសប្រជាជនភូមិមាត់ព្រៃ ភូមិអណ្តូងជីមីន ភូមិម៉ាកប្រាង្គ ភូមិកំពង់ក្រុង ភូមិកំពង់ត្រែង ភូមិព្រៃត្នោត និងភូមស្នំប្រាំពីរ មានការបារម្ភ ខ្វាចបាក់ទំនប់ និងបាក់ភ្នំនាថ្ងៃអនាគតដោយសារ គំរោងវារីអគ្គិសនីនេះ ដែលអាចបំផ្លាញ់ដំណាំ ទ្រព្យសម្បត្តិផ្ទះសំបែង និងអាចសំលាប់ជីវិតសត្វនិងមនុស្សទៀតផង (យោងតាមការធ្វើបទសំភាសន៍ជាមួយ ប្រជាជនតាមភូមិខាងលើ នៅខែកញ្ញា ២០០៦ នេះ ដោយក្រុមសិក្សារបស់សាវ៉ាក់) ។

➢ *<u>វិធានការគាត់បន្ថយ</u>*

ក្រុមហ៊ុនត្រូវតែធ្វើការសិក្សារចនាបថ្នង់គំរោងដែលអាចធានាមិនអោយមានការបាក់ទំនប់ ការបាក់ភ្នំក្នុងតំបន់គំរោងវារីអគ្គិសនីកំចាយនេះ ។

ក្រុមហ៊ុនត្រូវធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់ទំនប់ ការបាក់ភ្នំ ឬការរញ្ជួយដីក្នុងតំបន់គំរោង ដល់ប្រជាជនដែលរស់នៅតាមដងស្ទឹងទីកឈូ និងព្រែកកំចាយ និងតំបន់ក្បែរខាងគំរោងកំចាយទាំងអស់អោយបានជ្រាបជាពតិមានន្ទូវ ហេតុការណ៍ខាងលើទាន់ពេលវេលាតាមតែអាចធ្វើទៅបាន ។

ក្រុមហ៊ុនត្រូវមានរៀបចំបំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះ សំភារៈ និងថវិការ ដើម្បីចានាការដោះស្រាយផលប៉ះពាល់ ដែលនឹងអាចកើតពីមហន្តរាយខាងលើនេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាព ។

៥.៣.២ ដំណាក់កាលសាងសង់គំរោង (Project Construction)

ក្នុងដំណាក់កាលនេះ គឺជាដំណាក់កាលមួយមានរយៈពេលរហូតដល់ ៤ ឆ្នាំ (យោងតាមកិច្ចសន្យារវាងក្រុមហ៊ុន ជាមួយរាជរដ្ឋាភិបាលកម្ពុជា) ហើយនឹងមានសកម្មភាពសាងសង់នូវសមាសភាពរបស់គំរោងជាច្រើន ដូចជា ការឈូសឆាយដី ការសាងសង់ផ្លូវចូលក្នុងការដ្ឋាន ការសាងសងទំនប់ទីមួយនិងទីពីរ អាគារផលិតថាមពលអគ្គសនីទាំងពីរកន្លែង ការិយាល័យ ផ្ទះបុគ្គលិកកម្មករ និងការសាងសង់បង្គោលនិងខ្សែនាំភ្លើងពីអាគារផលិតថាមពលទៅអនុស្ថានីយ៍នៅក្រុងកំពត ។ សកម្មភាពការងារទាំងនេះ នឹងអាចបង្កអោយមានការប៉ះពាល់អវិជ្ជមានសំខាន់ៗ មួយចំនួនមានដូចតទៅ :

៥.៣.២.១ ហេតុប៉ះពាល់អវិជ្ជមានចំពោះទេចនាសម្ព្រាស្ត្រ និង វិធានការកាត់បន្ថយ

- **<u>សណ្ឋានដី និងឋានលេខា (Morphology and Topography)</u>**

➢ *<u>ហេតុប៉ះពាល់អចិជ្ជមាន</u>*

ក្នុងដំណាក់កាលនេះនឹងបណ្តាលអោយប្រែប្រួលសណ្ឋានដីក្នុងទីតាំង គំរោងដោយសារសកម្មភាពឈូសឆាយ និងពង្រាបដី ស្រទាប់លើដែលមានគំរបព្រៃឈើនៅតំបន់អាងទីមួយ និងដីចំការដំណាំមួយចំនួននៅតំបន់អាងទីពីរ និងការធ្វើផ្លូវថ្មី ពីតំបន់យកថ្ម និងផ្លូវជំវិញតំបន់គំរោង ។

ដោយសារតំបន់នេះជាតំបន់ភ្នំអាចនឹងបណ្តាលអោយមានការប្រែប្រួលឋានលេខា (ខ្សែកំរីតកំពស់ដី) យ៉ាងខ្លាំង ដោយសារ សកម្មភាពពង្រាបដី ក្នុងការធ្វើទំនប់ ផ្លូវថ្នល់ចេញចូលតំបន់គំរោង អាគារផលិតថាមពលអគ្គិសនី កន្លែងសាងសង់អាគារសំរាប់ ទីស្នាក់ការ និងផ្ទះបុគ្គលិកកម្មកររបស់ក្រុមហ៊ុន ។

➢ *<u>ចិធានការកាត់បន្ថយ</u>*

ក្រុមហ៊ុននឹងធ្វើការឈូសឆាយតែទីតាំងចាំបាច់សំរាប់បំរើអោយការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងវារីអគ្គិសនី កំចាយ ដែលមានរៀបរាប់ក្នុងរចនាបួងំលំអិត ។

ការដ្ឋានយកដី ថ្ម ក្នុងតំបន់គំរោងត្រូវធ្វើការកែលំអ និងលប់ដីតាមស្រទាប់ដែលអាចដាំដុះឡើងវិញបានទៀតផង ។

- **<u>ការហូរច្រោះ និងគុណភាពដី</u>**

➢ *<u>ហេតុប៉ះពាល់អចិជ្ជមាន</u>*

ដោយសារតំបន់គំរោងកំចាយជាតំបន់ភ្នំ មានចំណោទចោទខ្លាំង (I=0.31) ដូចនេះ សារការឈូសឆាយ ដីដែលមានគំរបព្រៃឈើ នឹងងាយមានការហូរច្រោះដី នៅពេលមានភ្លៀងធ្លាក់ និងជាពិសេសរដូវវស្សា ។

ម្យ៉ាងវិញទៀត អាចនឹងបង្កអោយប៉ះពាល់ដល់គុណភាពដីស្រទាប់លើ Soil Quality ដែលធ្វើអោយបាត់បង់ជីវជាតិរបស់ដី បណ្តាលមកពីសកម្មភាពរបស់គំរោង ។

> *ចិធានការគាត់បន្ថយ*

ក្រុមហ៊ុននឹងឈូសឆាយដី ពង្រាបដី សំរាប់ការសាងសង់ ដោយគោរពតាមលក្ខណៈទំរងប្រភេទដី ដើម្បីទប់ស្កាត់ឬបន្ថយការហូរច្រោះដី ដោយសារសកម្មភាពសាងសង់របស់គំរោង ។

ក្រុមហ៊ុននឹងធ្វើ ការបង្ហាប់ដីក្នុងតំបន់សាងសង់អោយបានត្រឹមត្រូវតាមបទដ្ឋានការងារដី ។

ក្រុមហ៊ុននឹងដាំកំរាលរុក្ខជាតិ ស្មៅ ឬ កូនឈើ តាមជំរៀលជើងទេរក្នុងតំបន់ការដ្ឋានរបស់គំរោង ដើម្បីជួយបន្ថយការហូរច្រោះដី ។

- **ប្រព័ន្ធជលសាស្ត្រ (Hydrologycal System)**

> *ហេតុប៉ះពាល់អចិជ្ជមាន*

នៅក្នុងតំបន់គំរោងនេះ អាចនឹងមានការប្រែប្រួលដល់ប្រព័ន្ធទឹកលើដី និង គុណភាពទឹករបស់វា ដោយសារសកម្មភាពសាងសង់របស់គំរោង ។

ការសាងសង់ទនប់ទីមួយ និងទំនប់ទីពីរ នឹងមានផលប៉ះពាល់ដល់បរិមាណចាទឹកហូររបស់ស្ទឹងទឹកឈូ និងព្រែកកំពង់បាយ ។

ការកាប់ឆ្ការព្រៃ ឈូសឆាយដី ការបោះចោល សំណល់រឹង សំណល់រាវ លើទីវាលក្បែរប្រភពទឹកពីសំណាក់កម្មករគំរោង ជាពិសេស ការលេចធ្លាយនៃរ្យេងឥន្ធនៈ និងប្រេងរំអិល ពីគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់ បង្កអោយមានការបំពុលគុណភាពទឹកស្ទឹងកំចាយ និងព្រែកកំពង់បាយ ។ ការចុះងូតទឹករបស់កម្មកររាប់រយនាក់ក្នុងស្ទឹង ក៏ជាប្រភពបំពុលដល់គុណភាពទឹកផងដែរ ។

> *ចិធានការគាត់បន្ថយ*

ក្រុមហ៊ុននឹងសាងសង់ផ្លូវទឹកបង្វៀងការដ្ឋាន ដើម្បីផ្តល់ទឹកមកខ្សែទឹកខាងក្រោមបានធម្មតា និងបញ្ឈៀសការខូកករដីបំពុលគុណភាពទឹក ។

ការកាប់ឆ្ការព្រៃ ឈូសឆាយដី នឹងត្រូវធ្វើនៅរដូវប្រាំង ដើម្បីបន្ថយការហូរច្រោះដីខ្លាំង ។

ក្រុមហ៊ុននឹងអប់រំដល់បុគ្គលិក កម្មករអំពីការបោះបង់កាក សំណល់រឹង សំណល់រាវ ជាពិសេសការកំពុបប្រេងឥន្ធនៈ ប្រេងរំអិល នៅលើដី ដែលបណ្តាលអោយខូចគុណភាពដីនិងទឹកនៅក្នុងតំបន់គំរោង ។ ក្រុមហ៊ុនគ្រប់គ្រង និងការពារសំណល់រឹង-រាវគ្រប់ប្រភេទ មិនអោយបោះចោលនិងបង្ហូរចូលទៅក្នុងឬក្បែរទឹកស្ទឹង ឬព្រែកឡើយ ។

ក្រុមហ៊ុននឹងរៀបចំអោយមានប្រព័ន្ធទឹកស្អាតប្រើប្រាស់ដល់ទីតាំងការដ្ឋាន និងជំរុំ/ផ្ទះកម្មករ គ្រប់គ្រាន់បង្កលក្ខណៈងាយស្រួលដល់កម្មករក្នុងការ ងូត លាងដុះ ប្រាណ សំភារៈ និងសំលៀកបំពាក់ ។

- **ការរញ្ជួយដី (seismology)**

ការរញ្ជួយដីអាចនឹងបង្កឡើងដោយសារការបំផ្ទុះផ្ទាំងថ្ម នៅការដ្ឋានធ្វើទំនប់ ធ្វើផ្លូវចេញចូល និងសំណង់ផ្សេងៗទៀត ដោយតំបន់គំរោងជាតំបន់ភ្នំ ។

ការរញ្ជួយដីពីការបំផ្ទុះនេះអាចនឹងរអិលបាក់ផ្នែកខ្លះនៃកំពូលភ្នំនៅក្នុងតំបន់គំរោង ដែលពុំមានលក្ខណៈជាប់មាំ ។

ការរញ្ជួយដីពីការបំផ្ទុះនេះអាចបង្កគ្រោះថ្នាក់ដល់សត្ត និងមនុស្សផងដែរ ។

> *ចិធានតាមតាត់បន្ថយ*

ក្រុមហ៊ុននឹងសិក្សាអោយបានត្រឹមត្រូវនូវផលល់បាកនានាដែលនឹងអាចកើតចេញពីការបំផ្ទុះផ្សេងៗ ដើម្បីបំរើអោយការងារសាងសង់គំរោងវារីអគ្គិសនីកំចាយនេះ ។

ក្រុមហ៊ុននឹងកំណត់កំរិតរញ្ជួយ និងកំលាំងបំផ្ទុះ ដើម្បីបញ្ជៀសការបាក់រអិលភ្នំ និងដើម្បីកាត់បន្ថយសំលេងរំខានដល់សត្វព្រៃរស់នៅ ក្នុងតំបន់ឧទ្យានជាតិបូកគោ ។

ក្រុមហ៊ុនត្រូវផ្តល់ពតិមាន និងផ្សព្វផ្សាយ ដល់អាជ្ញាធ័រ និងសហគមន៍មូលដ្ឋាន នូវកាលបរិច្ឆេទ និងពេលវេលាបំផ្ទុះ ដើម្បីការពារសុវត្ថិភាពគ្រោះថ្នាក់ដល់មនុស្ស និងសត្វព្រៃ តំបន់កំចាយ ។

ការបំផ្ទុះត្រូវធ្វើនៅពេលថ្ងៃ ។

- **ការបំពុលខ្យល់**

> *ហេតុប៉ះពាល់អចិជ្ជមាន*

ដំណាក់កាលសាងសង់នេះ អាចនឹងបំពុលខ្យល់ដោយសារការដុតឈើ ដើម្បីសំអាតការដ្ឋាន និងផ្សែងដែលបំភាយចេញពីគ្រឿងចក្រសាងសង់ និងរថយន្តដឹកជញ្ជូនសំភារះ និងការបំផ្ទុះ សំរាប់ការងារសាងសង់របស់គំរោង ។

> *ចិធានតាមតាត់បន្ថយ*

ក្រុមហ៊ុននឹងមិនធ្វើការដុតបំផ្លាញឈើដែលកាប់ក្នុងផ្ទៃអាងទីមួយ ទៅតាមបទដ្ឋានបច្ចេកទេស ដើម្បីការពារការឆេះរាលដាលព្រៃឈើក្បែរខាង ។

ឈើដែលមានអង្កត់ផ្ទឹតចាប់ពី ៣០០មម ឡើងទៅនោះក្រុមហ៊ុននឹងយកប្រើប្រាស់អោយអស់លទ្ធភាពក្នុងការងារសាងសង់ ហើយក្រុមហ៊ុននឹងសហការជាមួយ រដ្ឋបាលព្រៃឈើ និងអ្នកកែច្នៃនិងប្រើប្រាស់ឈើ ដើម្បីលក់បើមានការចាំបាច់ ។ ធ្វើយ៉ាងនេះ អាចចំណេញប្រាក់ផង និងកាត់បន្ថយការបំពុលបរិយាកាសផង ។

ក្រុមហ៊ុននឹងប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានការបញ្ចេញផ្សែងតិច ដើម្បីកាត់បន្ថយការបំពុលខ្យល់ក្នុងតំបន់នោះ ។

ក្រុមហ៊ុននឹងជ្រើសរើសជាតិផ្ទុះដែលមិនបង្កការបំពុលខ្យល់ខ្លាំង ។

- **ការបំពុលទឹក**

> *ហេតុប៉ះពាល់អចិជ្ជមាន*

ដោយសារសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អាចនឹងបំពុលគុណភាពទឹកស្ទឹងទឹកឈូ ព្រែកកំពង់បាយ និងអាចបំពុលដល់តំបន់ឆ្នេរពេលដែលមានចរន្តទឹកហូរខ្លាំងពីស្ទឹងទឹកឈូ ។ ការបំពុលគុណភាពអាចបង្កឡើងដោយ (១)

កកវដីកើតចេញពីការខួងឬជីកដី និងការបំផ្ទុះថ្មភ្នំ . (២) កាកសំណល់រឹង កមពីសំណល់សំភារៈសាងសង់ និង សំណល់មកពីបុគ្គលិក កម្មករក្រុមហ៊ុន . និង (៣) សំណល់រាវ មកពីការហៀរ ឬលេចជាតិប្រេងពីគ្រឿងចក្រ និងរថយន្ត) ។

ម្យ៉ាងទៀត អាចនឹងបំពុលគុណភាពទឹក ដោយសារការហូរច្រោះដី ចេញពីការយកចេញនូវគំរបក្នុងជាតិ ដូចជាការកាប់ព្រៃ ការឈូសឆាយដី ក្នុងតំបន់គំរោងទាំងមូល ។

➢ *<u>វិធានការគាត់បន្ថយ</u>*

ក្រុមហ៊ុនមិនធ្វើការឈូសឆាយទ្រង់ទ្រាយធំនៅរដូវវស្សាទេ ព្រមទាំងធ្វើរបាំងការពារកកវដី កុំអោយសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ ។

ក្រុមហ៊ុននឹងចាត់វិធានការយ៉ាងហ្មឺងម៉ុតក្នុងការគ្រប់គ្រង កាកសំណល់រឹង សំណល់រាវ ដោយសាងសង់បង្គន់អនាម័យ ព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសំរាម យកទៅចោល នៅទីតាំងដែលមានសុវត្ថិភាពដល់បរិស្ថាន និងសង្គម។ ក្រុមហ៊ុននឹងសាងសង់អាងប្រព្រឹត្តិកម្មកាកសំណល់រាវសំរាប់សំអាតទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក ដែលស្ថាក់នៅ និងធ្វើប្រតិបត្តិការ និងថែទាំគំរោង ហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះ នឹងមានកំរិតតាម ស្តង់ដានៃការបញ្ចេញចោលសំរាប់ប្រភពការបំពុលដល់ប្រភពទឹកសាធារណៈ ដែលការពារដោយក្រសួងបរិស្ថាន ។

ក្រុមហ៊ុននឹងសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈអោយបានត្រឹមត្រូវ មិនអោយកំពុបលើដីនាំអោយហូរចូលក្នុងប្រភពទឹកស្ទឹង ព្រែកក្នុងតំបន់គំរោងទេ ។ ក្រុមហ៊ុននឹងប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូន ដែលមានគុណភាពល្អមិនលេចហូរជាតិ ប្រេង ឬខ្លាញ់មកលើដី និងប្រភពទឹកក្នុងតំបន់គម្រោង ។

- <u>ការបំពុលដី</u>

➢ *<u>ហេតុប៉ះពាល់អវិជ្ជមាន</u>*

ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អាចនឹងមានការបំពុលដីដោយសារការកំពុបប្រេងឥន្ធនៈដែលប្រើសំរាប់គ្រឿងចក្រ និងរថយន្តទាំងនោះទៅលើដី ព្រមទាំងការចោលសំណល់សំភារៈសំណង់ដែលមានជាតិពុលលើដី។ សំណល់ ឬការកំពុបលើដីនូវសារធាតុផ្ទុះ ដែលប្រើប្រាស់សំរាប់បំផ្ទុះថ្ម ក៏បង្កការបំពុលដីបានដែរ ។ សំណល់ប្រេង ខ្លាញ់ជាតិពុលផ្សេងៗ រំសេវផ្ទុះអាចបំពុលដីនៅក្នុងការដ្ឋានថ្មាល់ផង និងនៅតំបន់ក្បែរខាងដោយសារទឹកហូរនាំទៅដល់ផងដែរ ។

➢ *<u>វិធានការគាត់បន្ថយ</u>*

ក្រុមហ៊ុននឹងសាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈអោយបានត្រឹមត្រូវ មិនអោយកំពុបលើដីទេ ។

ក្រុមហ៊ុននឹងចាត់វិធានការយ៉ាងតឹងរឹងក្នុងការប្រើប្រាស់ប្រេងឥន្ធនៈដូចជាមិនអោយចាក់ប្រេងម៉ាស៊ូតចាស់ៗ (ប្រេងបាត) ចោលទៅលើដី ប្រេងម៉ាស៊ូតចាស់ៗនេះ នឹងប្រើ ប្រាស់កែច្នៃទៅជាគ្រឿងចំហេះផ្សេងទៀត ។
ក្រុមហ៊ុននឹងចាត់វិធានការយ៉ាងហ្មឺងម៉ុតក្នុងការគ្រប់គ្រង កាកសំណល់រឹង សំណល់រាវ ដែលសេសសល់ពីការដ្ឋាន សាងសង់ និងរៀបចំប្រមូលសំណល់រឹង និងសំរាម យកទៅចោលនៅទីតាំងដែលមានសុវត្ថិភាពដល់បរិស្ថាន និងសង្គម ។

- <u>សំលេង និង រំញ័រ</u>

➢ *<u>ហេតុប៉ះពាល់អវិជ្ជមាន</u>*

ក្នុងសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អាចនឹងធ្វើអោយរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ភ្សៀវទេសចរណ៍ និង ពពួកសត្វព្រៃ ដែលមាននៅក្នុងនិងជុំវិញទីតាំងគំរោង ដោយសារមានសំលេងខ្ទាំងពីគ្រឿងចក្រ រថយន្ត ម៉ាស៊ីនគ្រប់ប្រភេទពេលកំពុងធ្វើការងារ ការបំផ្ទុះថ្ម ការកាប់រំលំដើមឈើធំ១ ។ ល ។

> *ចិធានការកាត់បន្ថយ*

ក្រុមហ៊ុននឹងប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូន ដែលមានសំលេងតិច ។

ក្រុមហ៊ុននឹងប្រើប្រាស់គ្រឿងផ្ទុះក្នុងកំរិតសមស្របទៅនឹងបរិស្ថានរបស់តំបន់ឧទ្យានជាតិ ដែលជាជំរកសត្វព្រៃរស់នៅ និងតំបន់ទេសចរណ៍ធម្មជាតិ ។

ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃប៉ុណ្ណោះដោយមិនធ្វើការរំខានដល់ប្រជាពលរដ្ឋ ភ្សៀវទេសចរណ៍ និងសត្វព្រៃក្នុងតំបន់គំរោង ។

៥.៣.២.២ ហេតុប៉ះពាល់អវិជ្ជមានទំនោះទទទានអេកូឡូស៊ី និង វិធានការកាត់បន្ថយ

- **មច្ចាជាតិ**

> *ហេតុប៉ះពាល់អចិជ្ជមាន*

ដំណាក់កាលសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងនេះ អាចនឹងធ្វើអោយប្រែប្រួលបរិមាណធាទឹក និងគុណភាពទឹកស្ទឹងកំចាយ និងព្រែកកំពង់បាយ ដោយសារសកម្មភាពសាងសង់ ។ មានការបង្ខាំងទឹក ការហូរច្រោះដី និងការចោលសំណល់ រឹង-រាវលើទីវាល និងក្បែរមាត់ស្ទឹង ជាហេតុធ្វើអោយប៉ះពាល់តិចតួចដល់ធនធានត្រីទឹកសាប និងទឹកភ្សៀវក្នុងតំបន់នេះ ។ ការរារាំងនៃផ្លូវផ្ទាស់ប្តូរទីរបស់ត្រី ដោយសារទំនប់ទាំងពីររបស់គំរោង ក៏បណ្តាលអោយមានផល ប៉ះពាល់ដល់ប្រភេទមច្ចាជាតិមួយចំនួន ។ តាមការសាកសួរពីប្រជាជនក្នុងតំបន់គំរោងនិងការថតរូបជាក់ស្តែង ឃើញថាស្ទឹងទឹកឈូមានប្រភេទត្រីឆ្ពាន់ ដែលអ្នកទីក្រុងហៅថា " ត្រីនាគ " រស់នៅតាមខ្សែទឹកខាងលើ និងត្រីស្តោង់រស់នៅខ្សែទឹកខាងក្រោម ក្នុងតំបន់ទឹកភ្សៀវនៃព្រែកកំពង់បាយ ។

> *ចិធានការកាត់បន្ថយ*

ក្រុមហ៊ុននឹងសាងសង់ផ្លូវទឹកបង្វៀងការដ្ឋានទំនប់ ដើម្បីមានផ្លូវទឹកសំរាប់ត្រីធ្វើដំណើរចុះឡើងបាន និងផ្តល់ទឹកមកខ្សែទឹកខាងក្រោមបានធម្មតា ព្រមទាំងបញ្ជៀសការខូកករដី បំពុលគុណភាពទឹកពុំរំខានដល់ការរស់នៅ និងបន្តកំនើតចំពោះត្រីដែលមាននៅក្នុងតំបន់គំរោងនេះ ។

ក្រុមហ៊ុននឹងសាងសង់សំណង់សិលប្បៈការសំរាប់អោយត្រីឆ្លងកាត់បាន តាមការរចនាប្លង់ត្រឹមត្រូវ បើមានការស្នើសុំពីរាជរដ្ឋាភិបាល និងអ្នកឯកទេសជលផលជាតិ និងអន្តរជាតិ ។

ក្រុមហ៊ុននឹងអប់រំដល់បុគ្គលិក កម្មករអំពីការបោះបង់កាក សំណល់រឹង សំណល់រាវ ជាពិសេសការកំពុបប្រេងឥន្ធនៈ ប្រេងរំអិល នៅលើដី ដែលបណ្តាលអោយខូចគុណភាពដីនិងទឹកនៅក្នុងតំបន់គំរោង ។ ក្រុមហ៊ុនគ្រប់គ្រង និងការពារសំណល់ រឹង-រាវគ្រប់ប្រភេទ មិនអោយបោះចោលនិងបង្ហូរចូលទៅក្នុងប្មក្បែរទឹកស្ទឹង ឬព្រែកឡើយ ។

- **ធនធានព្រៃឈើ និងជំរកសត្វព្រៃ**

> *ហេតុប៉ះពាល់អវិជ្ជមាន*

ដោយតំបន់គំរោងកំចាយស្ថិតនៅក្នុងឧទ្យានជាតិបូកគោ ដែលគ្របដណ្តប់ដោយព្រៃឈើពីរប្រភេទគឺ ព្រៃស្រោង និងព្រៃល្បាយប្ញស្សី យោងតាមផែនទីប្រភេទព្រៃឈើរបស់ JICA ឆ្នាំ ២០០២ មាត្រដ្ឋាន ១/១.000.000 និងការចុះសិក្សាផ្ទាល់បេស់ក្រុមការងាររបស់សាវ៉ាក់ ដូចនេះព្រៃឈើទាំងពីរប្រភេទខាងលើក្នុងអាងទីមួយរបស់គំរោងនឹងត្រូវលិចបាត់បង់ទាំងស្រុង ដែលក្នុងនោះមានព្រៃស្រោងចំនួន ១៤១៧ ហ.ត និងព្រៃល្បាយប្ញក្សីចំនួន ១៤០ ហ.ត ។ ការបាតបង់ព្រៃក្នុងអាងវារីអគិសនីនេះ បង្កអោយមានផលប៉ះពាល់អវិជ្ជមានខ្លាំងបង្ហូរដល់ធនធានព្រៃឈើនៃឧទ្យានជាតិបូកគោ និងនាំទៅដល់ការបាត់បង់ជំរកសត្វព្រៃក្នុងតំបន់នេះ ដែលជាការព្រួយបារម្ភ និង សោកស្តាយរបស់ប្រជាជន និងរាជរដ្ឋាភិបាលចំពោះសម្បត្តិបរិស្ថានធម្មជាតិរបស់មាតុភូមិកម្ពុជានៅឧទ្យានជាតិបូកគោនេះ ។ សព្វថ្ងៃនេះតំបន់ឧទ្យានជាតិត្រូវបានយកចិត្តទុកដាក់ការពារ ថែរក្សាពីស្ថាប័នជាតិតំណាងដោយក្រសួងបរិស្ថាន និងស្ថាប័នអន្តរជាតិតំណាងដោយអង្គការក្រៅរដ្ឋាភិបាលមួយចំនួនរួមមាន World Wide Fund for Nature (WWF), WildAid, Wildlife Conservation Society (WCS) ជាដើម ព្រទាំងការចូលរួមគាំទ្រពីប្រជាជនមូលដ្ឋានទៀតផង ។ ដោយឡែកឧទ្យានជាតិបូកគោត្រូវបាន ធ្វើការអភិរក្ស ថែរក្សាយ៉ាងតឹងរឹងដោយមានកិច្ចសហប្រតិបត្តការពីគាំទ្របច្ចេកទេសពី WCS ។

ព្រៃឈើទាំងនេះជាជំរកសត្វព្រៃជាច្រើន ដូចនេះសកម្មភាពសាងសង់គំរោងនេះនឹងប៉ះពាល់ដល់សត្វព្រៃ និងជំរករបស់វា ។

> *ទិដានតារតាត់បន្ថយ*

ក្រុមហ៊ុននឹងធានាមិនកាប់ព្រៃឈើនៅក្រៅអាងទឹកទីមួយ និងនៅក្រៅពីទីតាំងសង់ហេដ្ឋារចនាសម្ព័ន្ធដែលមានបង្ហាញនៅក្នុងប្លង់រចនាគំរោងលំអិត ។

ក្រុមហ៊ុននឹងធ្វើការពិភាក្សាជាមួយផ្នែកឧទ្យានជាតិ ដើម្បីរកទីតាំងសមស្របក្នុងតំបន់ក្បែរខាងព្រៃដែលបាត់បង់ដោយសារសកម្មភាពគំរោងសំរាប់ដាំឈើ ដាំប្ញស្សី ទុកជាជំរកដល់សត្វព្រៃផង និង ដើម្បីរក្សាលំនឹងអេកូឡូស៊ីបរិស្ថានក្នុងឧទ្យានជាតិទាំងមូលផង ។

ក្រុមហ៊ុននឹងធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និង ក្រសួងបរិស្ថានដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអិវជ្ជមានដែលនឹងកើតមានឡើងជាយថាហេតុលើព្រៃឈើដែលនៅជាប់នឹងតំបន់គំរោង ក្នុងដំណាក់កាលនៃការសាងសង់នេះ ។

- **ជីវសាស្ត្រ សត្វព្រៃ**

> *ហេតុប៉ះពាល់អវិជ្ជមាន*

ដូចដែលបានពិពណ៌នាពីខាងលើរួចមកហើយ តំបន់គំរោងនេះមានសត្វព្រៃជាច្រើនប្រភេទដែលរស់នៅ ហើយប្រភេទសត្វមួយចំនួនកំពង់ត្រូវបានធ្វើការអភិរក្សដូចជា ខ្លាធំ ដំរី ខ្លាឃ្មុំ ទោចជាដើម ។ ដូចនេះដោយ សារសកម្មភាពសាងសង់ទំនប់វារីអគ្គិសនី អាងស្តុកទឹក និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត នឹងមានការផ្លាស់ប្តូរទីជំរក ឬថយចុះសត្វព្រៃមួយចំនួនដែលមាននៅក្នុងតំបន់គំរោង ។ ម្យាំងទៀត កាប់ឆ្ការគំរបព្រៃឈើ ការឈូសឆាយដី ការបំផ្ទុះថ្ម ការដឹកញ្ជូនសំភារៈសាងសង់

នឹងនាំអោយមានការភ័យខ្លាចដល់សត្វព្រៃទាំងនោះ ដោយសារមានសំលេងរំខានខ្លាំងៗ ចេញពីម៉ាស៊ីន គ្រឿងយន្ត និងគ្រឿងផ្ទុះទាំងនោះ ។

ក្រុមហ៊ុនត្រូវការជ្រើសរើសនូវបុគ្គលិកកម្មករវាប់រយនាក់ចូលមកធ្វើការនៅតំបន់នេះ សំរាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង នាំអោយនឹងអាចមានសកម្មភាពបរបាញ់ ឬ ចាប់សត្វព្រៃពីសំណាក់បុគ្គលិកកម្មករគំរោងទាំងនោះ នឹងអាចកើតមានផងដែរ ។

➢ *<u>វិធានការគោរព់បន្ថយ</u>*

ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសំរាប់ការងារទាំងឡាយណាដែលបង្កសំលេង និងរំញ័រ ដើម្បីកុំអោយមានការរំខាន ឬផ្ដើលសត្វព្រៃក្នុងតំបន់គំរោងនិងតំបន់ក្បែរខាង ។

ក្រុមហ៊ុនត្រូវកំណត់ភិរតរញួយ និងកំលាំងបំផ្ទុះ និង ប្រើប្រាស់ម៉ាស៊ីនដែលមានសំលេង និងរំញ័រតិច ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃទាំងនេះ ។

ក្រុមហ៊ុននឹងហាមឃាត់ដាច់ខាតដល់បុគ្គលិក កម្មកររបស់ ខ្លួនក្នុងការប្រមាញ់សត្វព្រៃនៅក្នុងតំបន់គំរោង ។ អប់រំ និងដាក់វិន័យដល់កម្មករគំរោងមិនអោយធ្វើការចាប់ឬបរ បាញ់សត្វព្រៃនិងធ្វើចរាចរណ៍សត្វព្រៃនៅក្នុងតំបន់នេះឡើយ ។

- **<u>តំបន់ឧទ្យានជាតិបូកគោ</u>**

➢ *<u>ហេតុប៉ះពាល់អតិថិជន</u>*

នៅក្នុងដំណាក់កាលសាងសង់នេះអាចនឹងធ្វើអោយប៉ះពាល់ដល់ឧទ្យានជាតិបូកគោ ដោយសារតំបន់គំរោងស្ថិតនៅក្នុងទឹកដី នៃឧទ្យាននេះទាំងស្រុង ហើយការលិចលង់ដីឧទ្យានដោយអាងទឹមួយមានប្រមាណ ១.៤% នៃផ្ទៃដីឧទ្យានទាំងមូល។ ដូចនេះដោយសារសកម្មភាពសាងសង់គំរោងនឹងបង្កអោយមានផលប៉ះពាល់ដល់ អេកូឡូស៊ីរបស់ឧទ្យាន ដោយសារការកាប់ឆ្ការព្រៃឈើ ការឈូសឆាយដី សំលេងពីគ្រឿងចក្រ ភាពខ្សោវខ្វាំនៃក្រុមកម្មករ ការបំពុលខ្យល់ ប្រភពទឹក ដោយសំណល់បញ្ចេញចោលពី ការងារសាងសង់ និងចេញពីមនុស្ស ព្រទាំងការទន្រ្ទានចូល ក្នុងព្រៃនៃក្រុមកម្មករក្រោយពីការងារ ដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្វជាដើម ។

ម្យ៉ាងវិញទៀតទទឹមគ្នានៃការងារសាងសង់របស់គំរោងអាចនឹងមានការទន្រ្ទានកាន់កាប់យកដីព្រៃ ដីឧទ្យានជាតិដែលនៅក្បែរខាងតំបន់គំរោង ពីសំណាក់ជនឈ្មួញតឱកាស ដែលបង្កអោយមានការធ្លាក់ចុះបរិស្ថានក្នុងតំបន់ឧទ្យានជាតិបូកគោថែមទៀត ។

➢ *<u>វិធានការគោរព់បន្ថយ</u>*

ក្រុមហ៊ុននឹងកំណត់ពេលវេលាធ្វើការតែពេលថ្ងៃសំរាប់ការងារទាំងឡាយណាដែលបង្កសំលេង និងរំញ័រ ដើម្បីកុំអោយមានការរំខាន ឬផ្ដើលសត្វព្រៃក្នុងតំបន់គំរោងនិងតំបន់ក្បែរខាង ។

ក្រុមហ៊ុនត្រូវកំណត់ភិរតរញួយ និងកំលាំងបំផ្ទុះ និង ប្រើប្រាស់ម៉ាស៊ីនដែលមានសំលេង និងរំញ័រតិច ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃទាំងនេះ ។

ក្រុមហ៊ុននឹងសាងសង់អាង បង្គន់អានាម័យសំរាប់អ្នកធ្វើការទាំងអស់នៅក្នុងការដ្ឋាន និងជំរុំស្នាក់នៅរបស់គំរោង រៀបចំប្រពន្ធ័ប្រមូលសំណល់រឹង និងសំរាម យកទៅចោលនៅទីតាំងដែលមានសុវត្ថិភាពដល់បរិស្ថាន និងសង្គម ជាពិសេសមិនអោយប៉ះពាល់ដល់បរិស្ថានរបស់ឧទ្យានជាតិឡើយ ។

ក្រុមហ៊ុននឹងធ្វើការអប់រំនិងដាក់វិន័យដល់កម្មករគំរោងមិនអោយធ្វើការទន្រ្ទានព្រៃក្នុងតំបន់ឧទ្យាន ដើម្បីចាប់ប្អូបរបាញ់សត្វព្រៃ ។

ក្រុមហ៊ុននឹងសហការជាមួយតំណាងឧទ្យានុរក្ស ក្រសួងបរិស្ថាន ក្រសួងដែនដីនគរូបនីយកម្មនិងសំណង់ និងស្ថាប័នជាប់ទាក់ទងដទៃទៀត ការពារ និងទប់ស្កាត់កុំអោយមានការរំលោភកាន់កាប់ដីព្រៃ ក្នុងនិងក្បែរខាងតំបន់គំរោង ។

៥.៣.២.៣ ហេតុប៉ះពាល់អវិជ្ជមានទំនោះបរិស្ថានសង្គម/សេដ្ឋកិច្ច និង វិធានការកាត់បន្ថយ

- <u>ការប្រើប្រាស់ដី និងការតាំងលំនៅដ្ឋានឡើងវិញ</u>

➢ *<u>ហេតុប៉ះពាល់អវិជ្ជមាន</u>*

នៅក្នុងដំណាក់កាលសាងសង់នេះ អាចនឹងប៉ះពាល់ដល់ការប្រើប្រាស់កាន់កាប់ដីរបស់ប្រជាពលរដ្ឋក្នុងតំបន់ទីកឈូដែលចំលើទីតាំងទំនប់ទីពីរ យោងតាមប្លង់រចនាគំរោង ដែលក្រុមហ៊ុនស្នើសូម ធ្វើការអភិវឌ្ឍន៍ ដាក់ជូនចំពោះ រាជរដ្ឋាភិបាលកម្ពុជា ត្រូវការដីសំរាប់សាងសង់ទំនប់ទីពីរ ការិយាល័យ រោងជាង ផ្ទះស្នាក់នៅរបស់បុគ្គលិកកម្មករ និងការសាងសង់ផ្លូវចេញចូលក្នុងតំបន់គំរោង ផ្លូវពីការដ្ឋានយកថ្ម និងការសង់បង្គោលនាំភ្លើងពីវារីអគ្គិសនីកំចាយ ទៅស្ថានីយ៍រងនៅក្រុងកំពត ។

នៅផ្នែកខាងស្តាំស្ទឹង មានដីចំការចំនួន ១៩ម្ចាស់ ដែលមានផ្ទៃក្រឡារងផលប៉ះពាល់ផ្ទាល់ប្រមាណ ៥០ហ.ត ដោយសារចនាសម្ព័ន្ធតំបន់ទំនប់ទីពីរ (រាប់ចាប់ពីទំនប់ទីពីរ រហូតដល់ស្ពានដែក) ។ មានកម្មករចំនួន៣៨គ្រួសារដែលកំពុងធ្វើចំការនិងរស់នៅលើដីទាំង១៩ម្ចាស់នេះ ហើយដែលនឹងប្រឈមនឹងការបាត់បង់ការងារ និងជំរករស់នៅរបស់គាត់ ។ នៅផ្នែកខាងឆ្វេងស្ទឹងនៅក្នុងទឹកដីភូមិមាត់ពាម មានដីចំការចំនួន ១៣ម្ចាស់ដី ដែលនឹងត្រូវប៉ះពាល់ដោយការសាងសង់ផ្លូវចេញចូលរបស់គំរោងឆ្លងកាត់ចំការរបស់ពួកគាត់ យោងតាមប្លង់រៀបចំគំរោងរបស់ក្រុមហ៊ុន ។

➢ *<u>វិធានការកាត់បន្ថយ</u>*

ដំណោះស្រាយចំពោះដីចំការ លំនៅដ្ឋានដែលនឹងត្រូវប៉ះពាល់ដោយការងារសាងសង់គំរោងវារីអគ្គិសនីកំចាយនេះជាបន្ទុករបស់ក្រុមហ៊ុន និងរាជរដ្ឋាភិបាលកម្ពុជា ។ មិនទន្រ្ទានយកដីរបស់ប្រជាពលរដ្ឋដែលបានកាន់កាប់ ដោយសន្តិវិធី(យោងតាមច្បាប់ភូមិបាលមាត្រាលេខ ៣, ៥, ៨, ២៣, ២៥ និង ៣០) ឡើយដូចជា : ដីភូមិ ដីចំការ និងដីសហគមន៍ ។

ក្រុមហ៊ុននឹងចូលរួមសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ អាជ្ញាធរមូលដ្ឋាន និង អនុវត្តទៅតាមការសំរេចចិត្តរបស់រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលនូវទំនាស់ដីធ្លីទាំងឡាយ ដែលកើតមានដោយសារការប្រើប្រាស់ដីរបស់ប្រជាជនក្នុងទីតាំងគំរោង ។

ការទូទាត់ដល់ការបាត់បង់ដីប្រើប្រាស់ ខូចខាតលំនៅដ្ឋាន/ផ្ទះឃាមចំការ ដំណាំគ្រប់ប្រភេទ ត្រូវធ្វើការដោះស្រាយតាមបទដ្ឋាន និងការវាយតំលៃជាក់ស្តែង របស់គណៈកម្មាការរៀបចំការតាំងលំនៅដ្ឋានឡើងវិញរបស់រាជរដ្ឋាភិបាល ដែលជាទូទៅមានតំណាងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន និងអន្តរក្រសួងជាប់ទាក់ទងនឹងគំរោងអភិវឌ្ឍនោះ ។

ក្រុមហ៊ុននឹងខិតខំស្រូបយកកំលាំងពលកម្មពីប្រជាជនដែលបាត់បង់ការងារធ្វើចំការនិងរបររកស៊ីក្នុងតំបន់ទីកឈូនេះ អោយបានច្រើនតាមលទ្ធិភាពដែលអាចធ្វើបាន ។

- <u>ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន</u>

> <u>*ហេតុប៉ះពាល់អវិជ្ជមាន*</u>

ដំណាក់កាលសាងសង់គំរោងនេះ នឹងអាចមានការប៉ះពាល់ដល់មុខរបររបស់ប្រជាពលរដ្ឋមានរបរចិញ្ចឹមជីវិតក្នុងតំបន់ដូចជា អ្នកលក់ដូរនៅរមណីដ្ឋានទីកឈូ អ្នកកាប់ឬស្សី/ផ្តៅ/អូស និងអ្នករកអនុផលព្រៃឈើដទៃទៀត ដោយសារក្រុមហ៊ុនបិទផ្លូវ ឬហាមមិនអោយចូលទៅប្រកបរបរដូចមុនទៀត ឬហាមឃាត់ប្រជាពលរដ្ឋមិនអោយចូលក្នុងតំបន់ ដែលខ្លួនកាន់កាប់សំរាប់ការងារសាងសង់គំរោងនេះ។ នៅក្នុងតំបន់គំរោងសព្វថ្ងៃនេះប្រជាពលរដ្ឋអាចរកចំណូលបន្ថែម សំរាប់ជីវភាពរស់នៅរបស់គាត់ គឺការលក់ដូរផ្លែឈើ និងប្រមូលអនុផលព្រៃឈើ ។ តាមការចុះសិក្សាជាក់ស្តែងនៅ ខែកញ្ញា ឆ្នាំ២០០៦ របស់ក្រុមការងារសាវ៉ាក់ (SAWAC) មានប្រជាពលរដ្ឋលក់ដូរនៅរមណីយដ្ឋានទីកឈូចំនួន ៥២គូប (តែទិន្នន័យបានពីមន្ទីរទេសចរណ៍ខេត្តមាន ៣៤គូបដែលបានចុះបញ្ជី និងនៅដំណើរការដល់ឆ្នាំ ២០០៦ នេះ) និងមានប្រជាពលរដ្ឋចំនួន ១៤៥នាក់ (រាប់ថ្ងៃទី៤/៩/២០០៦) ដែលឡើងភ្នំចូលទៅក្នុងតំបន់គំរោង ដើម្បី កាប់ឬស្សី/ផ្តៅ/អូស និងរកអនុផលព្រៃឈើដទៃទៀត (តែតាមពតិមានពី ឧទ្យានជាតិបូកគោថាមានប្រមាណជា ២០០នាក់/មួយថ្ងៃ) ។

បន្ថែមពីលើនេះទៀត នឹងមានផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះ ជាពិសេសប្រជាពលរដ្ឋមានការ ភ័យខ្លាច និងមិនសូវចូលចិត្តរស់នៅជាមួយអ្នកចំណូលថ្មី ដោយសារក្រុមហ៊ុននាំកម្មករមកពីតំបន់ផ្សេងៗ ជនជាតិផ្សេងចូលមករស់នៅលើទីតាំងនេះ នឹងអាចកើតមានអំពើមិនសមស្របនឹងច្បាប់រដ្ឋ និងរបៀបរស់នៅរបស់សហគមន៍ ។

> <u>*ចិធានការគាត់បន្ថយ*</u>

ក្រុមហ៊ុននឹងសហការជាមួយឧទ្យានជាតិ និងក្រសួងទាក់ទងដែលដំណាងអោយរាជរដ្ឋាភិបាល ធ្វើការដោះស្រាយរកទីព្រៃឬស្សីក្រៅទីតាំងគំរោង ឬធ្វើការដាំព្រៃឈើនិងឬស្សីនៅតំបន់ក្បែរខាងនៃឧទ្យានបូកគោដើម្បីរក្សាតុល្យភាពបរិស្ថានក្នុងតំបន់ និងជាធនធានសំរាប់ប្រជាពលរដ្ឋបន្តរបរចិញ្ចឹមជីវិត ជាអ្នកកាប់ឬស្សី/ផ្តៅ/អូស និងអ្នករកអនុផលព្រៃឈើដទៃទៀតដូចពេលដែលមិនទាន់មានការសាងសង់គំរោង ។

ក្រុមហ៊ុននឹងសហការជាមួយមន្ទីរទេសចរណ៍រកដំណោះស្រាយដើម្បីរក្សាទុកទីតាំងលក់ដូរនៅទីកឈូ ឬ រកទីតាំងសមស្របនៅក្បែរទីតាំងចាស់ អោយអ្នកលក់ដូរទាំងនេះបន្តអាជីវកម្មដដែលដូចពេលមុន ។

ក្រុមហ៊ុននឹងខិតខំស្រូបយកកំលាំងពលកម្មពីប្រជាជនដែលបាត់បង់ការងារធ្វើចំការនិងរបររកស៊ីក្នុងតំបន់ទីកឈូនេះ អោយបានច្រើនតាមលទ្ធិភាពដែលអាចធ្វើបាន ។

ទំនៀមទំលាប់ និងប្រពៃណីរបស់ប្រជាពលរដ្ឋ ក្នុងតំបន់នោះ ត្រូវបានជួយការពារ និងយកចិត្តទុកដាក់ពីក្រុមហ៊ុន ដោយខិតខំស្វែងយល់ គោរពតាមទំនៀមទំលាប់ ការរស់នៅរបស់ប្រជាពលរដ្ឋ និងធ្វើការអប់រំ-ណែនាំបុគ្គលិក កម្មការរបស់ខ្លួន និងដាក់វិន័យតឹងរឹងបំផុត មិនអោយប្រព្រឹត្តិ អំពើល្មើសនឹងច្បាប់រដ្ឋ និងទំលាប់ប្រពៃណីមូលដ្ឋានរបស់ប្រទេសជាតិ និងសហគមន៍ នៅក្នុងតំបន់នោះឡើយ ។

ក្រុមហ៊ុននឹងសហការចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នមានសមត្ថកិច្ច ដើម្បីការពារឬកាត់បន្ថយអំពើទាំងនេះអោយបានលទ្ធផលល្អប្រសើរ ។

- **ប្រពៃណី វប្បធម៌ និង សាសនា**

➢ *<u>សេតុប៉ះពាល់អវិជ្ជមាន</u>*

ក្នុងដំណាក់កាលសាងសង់នេះ អាចប៉ះពាល់ដល់ប្រពៃណី វប្បធម៌ និងជំនឿ សាសនា និងទំលាប់ប្រពៃណីមូលដ្ឋានដែលមានស្រាប់របស់ប្រជាពលរដ្ឋ នៅក្នុងតំបន់នេះធ្លាប់គោរពបូជា ដោយសារក្រុមហ៊ុននាំកម្មករមកពីតំបន់ផ្សេងៗចូលមករស់នៅលើទីតាំងនេះ។ ម្យ៉ាងវិញទៀតការសាងសង់អាចប៉ះពាល់ដល់កន្លែងសការៈបូជាទាំងឡាយដូចជា ព្រៃ ឬទីទួលអ្នកតា អារក្ស សំណាក់ម្ចាស់ទឹកដីក្នុងតំបន់ ។ ល។ តាមការសាកសួររបស់ក្រុមការងារសារ៉ាំក់ ពីប្រជាជនក្នុងតំបន់គំរោងនេះមាន ទីទួលអ្នកតា សំណាក់ម្ចាស់ទឹកដីក្នុងតំបន់មួយចំនួនរួមមាន លោកតាបលង្គ លោកតាកំចាយ លោកតាក្រហមក និងលោកតាកូនភ្នំ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

ក្រុមហ៊ុនរក្សាទំនៀមទំលាប់ប្រពៃណី និង ជំនឿសាសនារបស់ប្រទេសកម្ពុជា និងរបស់ប្រជាពលរដ្ឋនៅក្នុងនិងជុំវិញទីតាំងគំរោង ដោយធ្វើការពិភាក្សារកដំណោះស្រាយជាមួយមេភូមិ និងចាស់ព្រឹទ្ធាចារ្យនៃភូមិដែលនៅជាប់តំបន់គំរោងដោយផ្ទាល់ និងភូមិក្បែរ ខាងដទៃទៀត ។

ក្រុមហ៊ុនអភិរក្សការពារព្រៃអ្នកតា ទីទួល/កន្លែងសការៈបូជាទាំងឡាយ ដែលមាននៅក្នុង និងក្បែរតំបន់គំរោង ។

ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិកកម្មករគំរោង អោយយល់ដឹងអំពីការថែរក្សាទំនៀមទំលាប់ប្រពៃណី វប្បធម៌ និងជំនឿសាសនារបស់ប្រទេសកម្ពុជា និងរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះ ។

- **ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត**

➢ *<u>សេតុប៉ះពាល់អវិជ្ជមាន</u>*

ក្នុងដំណាក់កាលសាងសង់ទំនប់វារីអគ្គិសនីតំចាយ នឹងមានផលប៉ះពាល់ដល់ផ្នែកផ្គត់ផ្គង់ទឹកស្អាត ជាពិសេសរដ្ឋាករទឹកក្រុងកំពត ដោយមានការបំពុលគុណភាពទឹកដោយសកម្មភាពសាងសង់ ។ ព្រោះថាស្ថានីយ៍បូមទឹកចូលទៅ រោងចក្រសំអាតនៅចំងាយប្រហែល ៥០០ម ពីទីតាំងទំនប់ទីពីរ ។ ការប៉ះពាល់ដល់គុណភាពប្រភពទឹកឈូនេះ ធ្វើអោយរដ្ឋាករទឹកកំពតមានការចំណាយទុនច្រើនសំរាប់សំអាតមុននឹងចែកចាយដលអ្នកប្រើប្រាស់ ។

ម្យ៉ាងវិញទៀតការពង្រីកផ្លូវចេញចូលរបស់គំរោងពីក្រុងកំពតទៅទីកឈូ និងមានផលប៉ះពាល់ដល់ប្រព័ន្ធបំពង់ទឹកស្អាតរបស់រដ្ឋាករទឹកក្រុងកំពត អាចនឹងបាក់បែកដោយកន្លែង ។

➢ *<u>វិធានការកាត់បន្ថយ</u>*

ក្រុមហ៊ុននឹងអនុវត្តវិធីសាស្ត្របច្ចេកទេស និងប្រើប្រាស់ឧបករណ៍ សំភារៈដើម្បីកាត់បន្ថយការបំពុលគុណភាពទឹកស្ទឹងកំចាយ ដោយសារសកម្មភាពសាងសង់គំរោងអោយនៅសល់តិចទាបទាមតែអាចធ្វើទៅបាន ។

ក្រុមហ៊ុននឹងត្រូវធ្វើការជូនដំណឹងច្បាស់លាស់អំពី ថ្ងៃ ខែ និងពេលវេលា ដល់រដ្ឋាករទឹកកំពត និងអ្នកប្រើប្រាស់ប្រភពទឹកឈូទាំងអស់ តាមពេលវេលាសមស្រប អំពីការងារសាងសង់ដែលអាចបង្កអោយមានការបំពុល គុណភាពទឹកស្ទឹងកំចាយនេះ ដើម្បីអោយរដ្ឋាករទឹកកំពត និងអ្នកប្រើប្រាស់ ប្រភពទឹកឈូទាំងអស់ត្រៀមលក្ខណៈដោះស្រាយបញ្ហានេះទៅតាមវិធីសាស្ត្រមួយចំនួន ។

ក្រុមហ៊ុននឹងធ្វើសហប្រតិការដោះស្រាយចំពោះបញ្ហាបំពង់ទឹកនេះជាមួយ រដ្ឋាករទឹក មន្ទីរឧស្សាហកម្មខេត្តអោយបានសមស្របតាមការជាក់ស្តែង ។

- <u>រមណីយដ្ឋាន/ទីកន្លែងកំសាន្ត (ចរាចរណ៍)</u>

➢ <u>*ហេតុប៉ះពាល់អវិជ្ជមាន*</u>

ដំណាកកាលសាងសង់តំរោងនឹងមានការរំខានដល់សកម្មភាពទេសចរណ៍នៅក្នុងតំបន់ទឹកឈូទាំងមូល ដូចជាការរំខានដោយសារភាពចង្អៀតនៃចរាចរ ការបំពុលខ្យល់ពីផ្សែងនិងធូលី សំលេងនិងរំញ័រ ការបំពុលទឹកឈូធ្វើអោយកកល្អក់ និងសោភ័ណភាពមិនល្អ ចេញពីសកម្មភាពសាងសង់ ។ ផលប៉ះពាល់នេះនឹងធ្វើអោយមានការថយចុះនៃទេសចរជាតិ និងអន្តរជាតិ ហើយមានការខាតបង់ដល់របរលក់ដូររបស់ប្រជាពលរដ្ឋនៅរមណីយដ្ឋាន និងកន្លែងកំសាន្តក្នុងតំបន់ទឹកឈូនេះ ព្រមទាំងថយចុះចំណូលទេសចររបស់ខេត្តកំពតមួយចំនួនផងដែរ ។

➢ <u>*វិធានការកាត់បន្ថយ*</u>

ក្រុមហ៊ុននឹងសហការជាមួយមន្ទីរពាក់ព័ន្ធធ្វើការដោះស្រាយសំរួលចរាចរក្នុងតំបន់ទឹកឈូនេះ ដូចជាពង្រីកផ្លូវចាស់ឬធ្វើផ្លូវវាង ព្រមទាំងមានផ្ទាំកំសញ្ញា និងភ្នាក់ងារបញ្ជាចរាចរទៀតផង ។

ក្រុមហ៊ុននឹងកំណត់ ពេលវេលាម៉ោងធ្វើការ និងថ្ងៃខែ អោយបានសមស្របតាមប្រតិទិន្ននៃថ្ងៃឈប់សំរាករបស់រាជរដ្ឋាភិបាលកម្ពុជា ។

ក្រុមហ៊ុននឹងធ្វើការលាង ឬបាចស្រោចទឹក លើថ្នល់ចេញចូលដែលឆ្លងកាត់រមណីយដ្ឋាន/កន្លែងកំសាន្ត មាននៅក្នុងតំបន់ទឹកឈូនេះ ដើម្បីកាត់បន្ថយការហុយផង់ធូលី ។

ក្រុមហ៊ុននឹងធ្វើការអប់រំដល់បុគ្គលិកដែលបញ្ជាត្រឿងចក្រ និងយានយន្តទាំងអស់ត្រូវធ្វើការប្រុងប្រយ័ត្ន នៅពេលបើកឆ្លងកាត់តំបន់ទឹកឈូនេះ និងត្រូវបើកបរដោយល្បឿនយឺត ដើម្បីបង្ការសគ្រោះថ្នាក់ចរាចរនានា ។

- <u>ផ្លូវគមនាគមន៍</u>

➢ <u>*ហេតុប៉ះពាល់អវិជ្ជមាន*</u>

ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់តំរោងនេះ អាចនឹងបង្កអោយប៉ះពាល់ដល់ការប្រើប្រាស់ផ្លូវគមនាគមន៍របស់ក្រុង កំពត និងផ្លូវលំរបស់សហគមន៍ក្នុងតំបន់ ។ ការដឹកជញ្ជូនសំភារៈ បរិក្ខា ត្រឿងចក្រ ចូលទៅទីតាំងតំរោង អាចបង្កអោយមានបញ្ហាបីចំនួនរួមមាន (១) ការបាក់ស្ពានឆ្លងកាត់ព្រែកកំពង់បាយ និងស្ពានដែកនៅខាងលើរមណីយដ្ឋានទឹកឈូ (២)

ការបែកឬស្រុតខូចផ្ទៃល់ និង (៣) ការកកស្ទះចរាចរ និង គ្រោះថ្នាក់ចរាចរលើបណ្តាញផ្លូវថ្នល់មួយចំនួនក្នុងក្រុង និងទីប្រជុំជន មុនចូលដល់ការដ្ឋាន សាងសង់របស់គំរោង ។

➢ *<u>វិធានការគោលបំណង</u>*

ក្រុមហ៊ុននឹងធ្វើការកែលំអផ្លូវដែលមានស្រាប់ និងសាងសង់ផ្លូវថ្មី ដែលអាចធានាដល់ការប្រើប្រាស់របស់គំរោង និងធានាមិនអោយមានការខូចខាត ឬបាក់បែកចូនចូរដល់ផ្លូវគមនាគមន៍របស់ក្រុង កំពត និងផ្លូវលំរបស់សហគមន៍ក្នុងតំបន់ ដោយសារសកម្មភាពដឹកជញ្ជូនបំពីរអោយការងារសាងសង់គំរោងវារីអគ្គិសនីនេះ ។

ក្រុមហ៊ុននឹងធ្វើការអប់រំដល់បុគ្គលិកដែលបញ្ជាគ្រឿងចក្រ និងយានយន្តទាំងអស់ត្រូវធ្វើការប្រុងប្រយ័ត្នគ្រប់ពេលវេលា ហើយក្រុមហ៊ុនធានានូវសុវត្ថិភាពក្នុងការដឹកជញ្ជូន (មិនលើសទំងន់នាំអោយខូចផ្លូវជាតិ ឬផ្លូវលំរបស់សហគមន៍) និងការធ្វើដំណើរលើផ្លូវនេះអោយ មានស្ថេរភាព ទាំងក្រុមហ៊ុននិងប្រជាជនផង (ល្បឿនបើកបរមិនអោយលើសពី ៤០គ.ម ក្នុង១ម៉ោង នៅក្នុងតំបន់ភូមិ និងទីប្រជុំជន ២០-៣០គ.ម ក្នុង១ ម៉ោង) និងដើម្បីបង្ការសគ្រោះថ្នាក់ចរាចរនានា ។

ក្រុមហ៊ុននឹងសហការជាមួយមន្ទីរពាក់ព័ន្ធធ្វើការដោះស្រាយសំរួលចរាចរក្នុងតំបន់មានការកកស្ទះ និងកន្លែងបត់ចូលការដ្ឋាន ដូចជាពង្រីកផ្លូវចាស់ ឬធ្វើផ្លូវវាំង ព្រមទាំងមានផ្ទាក់សញ្ញា និងភ្នាក់ងារបញ្ជាចរាចរទៀតផង ។

ក្រុមហ៊ុននឹងធ្វើការជួសជុលផ្លូវក្នុងតំបន់គំរោងអោយរាបស្មើ និង ធ្វើការថែរក្សាផ្លូវដែលខ្លួនបានប្រើប្រាស់ជាប្រចាំ និងដាក់សញ្ញាសំគាល់ចរាចរណ៍អោយបានត្រឹមត្រូវ និងគ្រប់គ្រាន់ ។

- <u>សុខភាពសាធារណៈ</u>

➢ *<u>ហេតុប៉ះពាល់អវិជ្ជមាន</u>*

ការងារសាងសង់របស់គំរោង អាចបង្កអោយមានការប៉ះពាល់ដល់សុខមាលភាព បុគ្គលិកកម្មកររបស់ក្រុមហ៊ុន ដោយសារ ការធ្វេសប្រហែស និងភាបគ្មានសុត្ថិភាពក្នុងការងារ ។ ការសាងសង់បង្គោល និងខ្សែនាំភ្លើង ចំងាយ ១២ គ.ម ដែលមានកំលាងភ្លើងខ្ពស់ ហៅថា high viltage transmission line ពីស្ថានីយ៍ផលិតភ្លើងទៅស្ថានីយ៍រង ក្នុងក្រុងកំពត ក៏អាចបង្កផលប៉ះពាល់ដល់សុខមាលភាពរបស់ប្រជាជនផងដែរ នៅពេលដំណើរការ ។

ក្នុងដំណាក់កាលសាងសង់នេះដែរ អាចបង្កអោយមានផលប៉ះពាល់ដល់សុខភាពបុគ្គលិក កម្មករ របស់គំរោង និងប្រជាពលរដ្ឋក្នុងតំបន់នេះ ដោយសារបុគ្គលិក កម្មកររបស់ក្រុមហ៊ុនអាចកើតជំងឺគ្រុនចាញ់ ជំងឺអេដស៍ ជំងឺកាមរោគ ជំងឺរបេង ជំងឺឆ្លងផ្សេង១ ហើយចំលងដល់អ្នកភូមិតាមរយៈភ្នាក់ងារចំលងរោគផ្សេង១ (ម៉ុស រុយ មេរោគ ។ល។) និងដោយការប្រាស្រ័យទាកទងគ្នាដោយផ្ទាល់ ។ ការសេពគ្រឿងស្រវឹងក៏អាចចាត់ទុកថាជាជំងឺឆ្លងមួយបានដែរ (ការសេពថ្នាំល្បែន) ។

➢ *<u>វិធានការគោលបំណង</u>*

ក្រុមហ៊ុននឹងរៀបចំសាងសង់ជំរុំស្នាក់នៅ ការផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធអនាម័យ និងមានកម្មវិធីអប់រំសុវត្ថិភាពការងារដល់ បុគ្គលិកកម្មកររបស់គំរោង ។ ក្រុមហ៊ុនប្រកាន់យកការរក្សាសុវត្ថិភាពជាចំបងក្នុងសកម្មភាពការងារប្រចាំថ្ងៃ ។

ក្រុមហ៊ុននឹងសាងសង់ បង្គោល និងខ្សែនាំភ្លើង តាមបទដ្ឋានបច្ចេកទេស (ឧទា. កំពស់ខ្សែទាបបំផុតពីផ្ទៃដីគឺ ៨ម និងមិនសង់ចំពីរលើលំនៅដ្ឋានប្រជាពលរដ្ឋ ជាដើម) ដែលធានាបានមិនបង្កគ្រោះថ្នាក់ដល់សុខភាព ប្រជាជនក្នុងមូលដ្ឋាន ។

ក្រុមហ៊ុននឹងរៀបចំអោយមានមណ្ឌលថែរក្សាសុខភាពបន្ថាន់ និងមានគ្រូពេទ្យដែលមានសមត្ថភាពអោយប្រចាំការនៅការដ្ឋាន និងជំរំស្នាក់នៅរបស់កម្មករ និង ត្រៀមថ្នាំពេទ្យនិងបរិក្ខាគ្រប់គ្រាន់ជាប្រចាំ សំរាប់ធ្វើការពិនិត្យ និងព្យាបាលជូនបុគ្គលិកកម្មកររបស់តំរោង ។

ក្រុមហ៊ុននឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិកកម្មកររបស់ខ្លួន ដើម្បីទប់ស្កាត់ជំងឺទាំងនោះកុំអោយឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់នោះ ជាពិសេសទប់ស្កាត់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន។

ក្រុមហ៊ុននឹងសហការជាមួយស្ថាប័នសុខាភិបាលនៅក្នុងតំបន់នេះ ដើម្បីការពារជំងឺឆ្លងផ្សេងៗ ករណីមានជំងឺប្លែកៗ និងគ្រោះថ្នាក់ធ្ងន់ធ្ងរកើតមានឡើង លើសពីសមត្ថភាពរបស់មណ្ឌលថែរក្សាសុខភាពបន្ថាន់ ។

- <u>សោភណ្ឌភាព</u>

➢ <u>*ហេតុប៉ះពាល់អតិថិជ្ជមាន*</u>

ការសាងសង់បង្គោល និងខ្សែនាំភ្លើង ចំងាយ ១២ គ.ម ដែលមានកំលាងភ្លើងខ្ពស់ ហៅថា high viltage transmission line ពីស្ថានីយ៍ផលិតភ្លើងទៅស្ថានីយ៍រង ក្នុងក្រុងកំពត ក៏អាចបង្កផលប៉ះពាល់ដល់សោភណ្ឌភាពរបស់តំបន់ទីកឈូ និងតាមដងផ្លូវមកក្រុងកំពត ។

➢ <u>*ឥរិយាបថគាត់បន្ថយ*</u>

សំរាប់ការសាងសង់បង្គោល និងខ្សែនាំភ្លើង ក្រុមហ៊ុននឹងជ្រើសយកទិសតំរង់អោយបានសមស្រប ដើម្បីបន្ថយការរំខានដល់ការមើលឃើញទេសភាពតាមដងផ្លូវ ពីសំណាក់អ្នកធ្វើដំណើរឆ្លងកាត់តំបន់នេះ ។

- <u>ហានិភ័យ (Risk)</u>

➢ <u>*ហេតុប៉ះពាល់អតិថិជ្ជមាន*</u>

ក្នុងដំណាក់កាលនេះអាចនឹងមានហានិភ័យដោយសារគ្រោះធម្មជាតិ ការធ្វេសប្រហែសផ្នែកសន្តិសុខ/អំពើភាវរកម្ម ឬសង្គ្រាម ។

ការកើតមានការរញួយដី ឬបន្ទុះភ្នំភ្លើងនៅក្នុងតំបន់តំរោង ការទទួលរងឥទ្ធិពលពីព្យុះទីហ្វុង ឬព្យុះផ្សេងទៀតពីឈូងសមុទ្រថៃ អាចបង្កអោយមានមហន្តរាយធំៗ ដូចជាការបាក់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់តំរោងដែលកំពុងសាងសង់ ការបាត់បង់ឬខូចខាតសំភារៈ និងគ្រឿងចក្រសាងសង់ ជាពិសេសការធ្វើអោយរងរបួស និងស្លាប់បាត់បង់ជីវិតដល់បុគ្គលិកកម្មករ ព្រមទាំងប្រជាពលរដ្ឋនៅក្នុង/ក្បែរខាងតំបន់តំរោង ។

ការកើតមានទូវការផ្ទុះសំភារៈគ្រឿងផ្ទុះ ឆេះប្រេងឥន្ធនៈនៅកន្លែងឬឃ្លាំងស្តុករបស់តំរោង និងការឆេះព្រៃក្នុងតំបន់តំរោងដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើភាវរកម្ម ក៏អាចបង្កអោយមានមហន្តរាយប/គ្រោះថ្នាក់ធំដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់តំរោង ធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង ។

ការកើតមានសង្គ្រាមឈ្នានពានលើបូរណភាពទឹកដីនៃប្រទេសកម្ពុជា ក៏ជាឧបសគ្គដល់ការងារសាងសង់តំរោង ឬសង្គ្រាមអាចបំផ្លាញតំរោងទាំងស្រុងក៏សឹងមាន ។

➢ *ចិធានការកាត់បន្ថយ*

ក្រុមហ៊ុននឹងធ្វើការសិក្សារចនាបួងវិស្វកម្ម និងគុណភាពការសាងសង់ ដែលអាចធានាមិនអោយមានការបាក់ទំនប់ និងការបាក់ភ្នំក្នុងតំបន់គំរោង វារីអគ្គិសនីកំចាយនេះ ។

ក្រុមហ៊ុននឹងប្រុងប្រយ័ត្នគ្រប់វិនាទីក្នុងការការពារសន្តិសុខចំពោះគ្រឿងផ្ទុះ និងការឆេះព្រៃ ឆេះប្រេង និងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នមានសមត្ថកិច្ចដើម្បីទប់ស្កាត់រាល់អំពើភាវរកម្មក្នុងតំបន់គំរោង ។

ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់ទំនប់ ការបាក់ភ្នំ ឬការរញ្ជួយដីក្នុងតំបន់គំរោង ដល់ប្រជាជនដែលរស់នៅតាមដងស្ទឹងទឹកឈូ និងព្រែកកំចាយ និងតំបន់ក្បែរខាងគំរោងកំចាយទាំងអស់អោយបានជ្រាបហេតុការណ៍ ខាងលើទាន់ពេលវេលាតាមតែអាចធ្វើទៅបានបើសិនជាមានហានិយភ័យបែបនេះកើតឡើង ។

ក្រុមហ៊ុននឹងបង្ហូរទឹកឱ្យអស់ពីអាង នៅពេលមានបញ្ហាគ្រោះថ្នាក់ដោយចៃដន្យ ដូចជា ការរញ្ជួយដី សង្គ្រាម និងកំលាំងរុញច្រានមកលើទំនប់ខ្លាំង ។

ក្រុមហ៊ុននឹងមានរៀបចំបំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះ សំភារៈ និងថវិការ ដើម្បីធានាការដោះស្រាយផលប៉ះពាល់ដែលនឹងអាចកើតពីមហន្តរាយខាងលើនេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាព ។

៥.៣.៣ ដំណាក់កាលប្រតិបត្តិ និងថែទាំគំរោង (Project Operation & Maintenance)

ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងនេះគឺ ជាដំណាក់កាលមួយមានរយៈពេលវែងជាងគេរហូតដល់ ៤០ឆ្នាំ យោងតាមកិច្ចសន្យាស្នើសុំរបសក្រុមហ៊ុន ដាក់ជូនទៅរដ្ឋាភិបាល ។ សកម្មភាពគំរោងក្នុងដំណាក់កាលនេះ នឹងអាចបង្កអោយមានការប៉ះពាល់បរិស្ថាន អវិជ្ជមានសំខាន់ៗ ដូចតទៅ :

៥.៣.៣.១ ហេតុប៉ះពាល់អវិជ្ជមានចំពោះធនធានរូបសាស្ត្រ និង វិធានការកាត់បន្ថយ

- ប្រព័ន្ធជលសាស្ត្រ (Hydrologycal System)

➢ *ហេតុប៉ះពាល់អចិជ្ជមាន*

ក្នុងដំណាក់កាលប្រតិបត្តិនិងថែទាំគំរោងវារីអគ្គិសនីនេះ អាចនឹងប៉ះពាល់ដល់ប្រព័ន្ធជលសាស្ត្រក្នុងតំបន់គំរោង និងខ្សែទឹកខាងក្រោម ដោយសារការបង្ខាំងទឹក និងការបច្ចេញទឹកពីទំនប់ទាំងពីររបស់គំរោង ។

ការបង្ខាំងទឹកដោយទំនប់ទាំងពីរ ដើម្បីស្តុកទឹកទុកអូសទូរបឺនភ្លើង ដែលអាចផលិតភ្លើងសរុប ១៩៣ មេហ្គាវ៉ាត់ នឹងបង្កអោយមានការប្រែប្រួលរបបទឹកហូរខុសពីមុន (ដែលវាហូរតាមបែបធម្មជាតិ) ចំពោះបណ្តាស្ទឹង ព្រែក អូរ ដែលទទួលទឹកពីស្ទឹងទឹកឈូ ។ ព្រែក អូរមួយចំនួននៅផ្នែកខាងក្រោមនៃទំនប់នឹងមានការខ្វះខាតទឹក ដោយកំពស់ទឹកលិចទាប និងល្បឿនទឹកហូរខ្សោយជាងមុន នៅរដូវវស្សាមុនពេលមានគំរោង ។ ដូចនេះកំរិតសាយភាយទឹករបស់ព្រែក និងអូរទាំងនោះ នឹងមានកំរិតទាបជាងមុន ដែលបណ្តាលអោយមានការថយចុះនៃអេកូឡូស៊ីរបស់ប្រព័ន្ធជលសាស្ត្រនៅបែកខាងក្រោមទំនប់វារីអគ្គិសនីកំចាយនេះ ។

➢ *ចិធានការកាត់បន្ថយ*

ក្រុមហ៊ុននឹងធ្វើប្រតិបត្តិការគំរោងយ៉ាងណា ដើម្បីបច្ចេញទឹកពីអាងស្តុកទឹកទាំងពីរអោយបានសមស្រប ទាំងរដូវ រស្សា និងរដូវប្រាំង ដើម្បីរក្សា អេកូឡូស៊ីរបស់ប្រព័ន្ធជលសាស្ត្រនៅបែកខាងក្រោមទំនប់ មិនអោយថយចុះខ្លាំង ឬមិនធ្វើអោយខូចខាតទាំងស្រុង ហៅថាប្រព័ន្ធជលសាស្ត្រងាប់ ឬស្ទឹងងាប់ ព្រែកងាប់នោះឡើយ ។

ក្រុមហ៊ុននឹងត្រូវបច្ចេញទឹកពីអាងស្តុកទឹកទីពីរយ៉ាងតិច ៦ម^3/វិនាទី នៅរដូវប្រាំង ដើម្បីរក្សាអេកូឡូស៊ីរបស់ព្រែកកំពង់បាយ យោងតាមការវិភាគលើទិន្នន័យហូររបស់ស្ទឹងទឹកឈូរយៈពេល ៣៤ឆ្នាំ (១៩៥៨-២០០១) របស់ក្រសួងធនធានទឹក និងឧតុនិយម រំហូរមធ្យមគឺ ៣.២ ម^3/វិនាទី នៅខែកុម្ភៈ (មើលតារាងទី ២) ។

- **<u>គុណភាពទឹកក្រោមដី និង លើដី</u>**

➢ ***<u>ហេតុប៉ះពាល់អវិជ្ជមាន</u>***

ចំពោះសកម្មភាពប្រតិបត្តិនិងថែទាំរបស់តំរោង អាចបង្កអោយមានការប៉ះពាល់ដល់គុណភាពទឹកក្រោមដី និងលើដី នៅតំបន់ក្បែរខាង និងខ្សែទឹកខាងក្រោម ។ ការលេចជ្រាបពីអាងស្តុកទាំងពីរ ចូលទៅទឹកក្រោមដី និងការបង្ហូរទឹកចេញតាមបំពង់ឆ្លងកាត់ទួរប៊ីន និងបំពង់លាងបាតអាងទាំងពីរ ព្រោះទឹកទាំងនោះខ្វះការរលាយអុកស៊ីសែន និងមានកួនស្អុយទៀតផង។ គុណភាពទឹកមិនល្អនេះនឹងប៉ះពាល់ដល់អ្នកប្រើប្រាស់ទឹកជាពិសេសរដ្ឋាភិបាលទឹកក្រុងកំពត និងប៉ះពាល់ការរស់នៅ និងបង្កកំណើតរបស់សត្វ និងរុក្ខជាតិទឹក នៅខាងក្រោមទំនប់នៃតំរោងនេះទៀតផង ។

ម្យ៉ាងវិញទៀតអាងស្តុកទឹករបស់តំរោងវារីអគ្គិសនីអាចកើតមានរុក្ខជាតិទឹកសង្រៃដូចជា ចក កំបោក និងសត្វល្អិតចង្រៃដូចជា មុស បាក់តើរ ដែលបង្កអោយមានរំហុតខ្លាំង ការបំពុលគុណភាពទឹកអាង និងការចំលង់ជំងឺផ្សេងៗដែលកើតចេញពីប្រភពទឹកមិនល្អនេះ ។

➢ ***<u>វិធានការគ្រប់គ្រង</u>***

ក្រុមហ៊ុននឹងធ្វើការគ្រប់គ្រង ការពារ និង ពិនិត្យតាមដាន មិនអោយមានការបំពុលគុណភាពទឹកក្នុងអាងទាំងពីរ ។

ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍ និងសំភារៈ និងអ្នកឯកទេស សំរាប់សំអាតរុក្ខជាតិទឹកសង្រៃនិងសត្វល្អិតចង្រៃដែលនឹងអាចកើត មាននៅក្នុងអាងស្តុកទាំងពីរបស់តំរោង ។

ក្រុមហ៊ុននឹងធ្វើការពិភក្សាជាមួយរដ្ឋាភិបាលទឹក មន្ទីរនិងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្តូរទីតាំងស្ថានីបូមទឹកសំរាប់យកទៅសំអាត ទៅនៅក្នុងទីតាំងអាងទីពីរវិញ ។

- **<u>ធនធានព្រៃឈើ និងជំរកសត្វព្រៃ</u>**

➢ ***<u>ហេតុប៉ះពាល់អវិជ្ជមាន</u>***

ក្នុងដំណាក់កាលប្រតិបត្តិការ និងថែទាំនេះ អាចនឹងប៉ះពាល់ដល់ជំរកសត្វព្រៃ ដោយសារសកម្មភាពរបស់បុគ្គលិកកម្មករដែលធ្វើប្រតិបត្តិការ និងថែទាំតំរោង ។ ការទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ដាក់អន្ទាក់ រកឃ្មុំ អាចបង្កអោយមានភ្លើងឆេះព្រៃ បាត់បង់ព្រៃឈើ និងជំរកសត្វព្រៃ ។

ការទន្ទ្រានកាន់កាប់ដីព្រៃនៅក្នុង និង ក្បែរខាង តំបន់តំរោង (ដែលជាតំបន់អភិរក្ស ព្រៃឈើ និងជំរកសត្វរបស់ឧទ្យានជាតិបូកគោ) ពីសំណាក់ បុគ្គលិក កម្មករដែលធ្វើប្រតិបត្តិការ និងថែទាំ តំរោង ឬអ្នកមកពីខាងក្រៅ ។

➢ *<u>វិធានការគ្រប់គ្រង</u>*

ក្រុមហ៊ុននឹងហាមឃាត់ដល់បុគ្គលិក កម្មកររបស់គំរោង មិនអោយទន្ទ្រានកាន់កាប់ដីព្រៃឈើ ដុះរានព្រៃ និងបំផ្លាញ់ជំរក សត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង។

ក្រុមហ៊ុននឹងធ្វើការអប់រំនិងហាមឃាត់ ដល់បុគ្គលិក កម្មកររបស់គំរោង មិនអោយទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ដាក់អន្ទាក់ រកឃ្មុំ និងដាក់ពិន័យដល់បុគ្គលិក កម្មករណាដែលប្រប្រឹត្តល្មើសនឹងការហាមឃាត់ខាងលើ ។

ក្រុមហ៊ុននឹងធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ ឧទ្យានជាតិបូកគោ និងក្រសួងបរិស្ថាន ដើម្បីកាត់បន្ថយ ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានលើដីព្រៃឈើ និងជំរកសត្វ ដែលនឹងកើតមានឡើងក្នុងដំណាក់កាលនេះ ។

ក្រុមហ៊ុននឹងបំពាក់នូវឧបករណ៍សំការៈ សំរាប់ពន្លត់អគ្គិភ័យ/ភ្លើងឆេះព្រៃ និងប្រព័ន្ធឧបករណ៍ដែលអោយ សញ្ញាពេលមាន អគ្គិភ័យកើតមានឡើង ។

- **<u>ជីវសាស្ត្រ សត្វព្រៃ</u>**

➢ *<u>ហេតុប៉ះពាល់អវិជ្ជមាន</u>*

ដោយសារការបាត់បង់ជំរកព្រៃមួយចំនួនក្នុងតំបន់អាងទឹមួយរបស់វារីអគ្គិសនីនេះ ធ្វើអោយមានការថយចុះសត្វព្រៃ ខ្លះដែរ ដែលមាននៅក្នុងតំបន់គំរោង ។ ម្យ៉ាងទៀត ផ្ទៃទឹកដ៏ធំធេងនៃអាងទឹមួយមិនអាចអោយសត្វព្រៃមួយចំនួនធំឆ្លងកាត់បាន ជាពិសេសចំពោះពាហនៈ ឬសត្វដើរលើដី ។

ការទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ដាក់អន្ទាក់ចាប់សត្វ ពីសំណាក់បុគ្គលិកកម្មករ ដែលធ្វើប្រតិបត្តិការ និងថែទាំគំរោង ក៏បណ្តាលអោយមានផលប៉ះពាល់ដក់សត្វព្រៃក្នុងតំបន់នេះផងដែរ ដូចជាថយចុះចំនួន និងបាត់បង់ពូជសត្វដែលកំពង់ធ្វើការ អភិរក្សដោយស្ថាប័នឧទ្យានជាតិ។

➢ *<u>វិធានការគ្រប់គ្រង</u>*

ក្រុមហ៊ុននឹងហាមឃាត់ដាច់ខាតដល់បុគ្គលិក កម្មកររបស់ ខ្លួនក្នុងការប្រមាញ់សត្វព្រៃនៅក្នុងតំបន់គំរោង ។ អប់រំ និងដាក់វិន័យដល់កម្មករគំរោងមិនអោយធ្វើការចាប់ឬបរ បាញ់សត្វព្រៃនិងធ្វើចរាចរណ៍សត្វព្រៃនៅក្នុងតំបន់នេះឡើយ ។

- **<u>ជីវសាស្ត្រដែលរស់នៅក្នុងទឹក / មច្ឆាជាតិ</u>**

➢ *<u>ហេតុប៉ះពាល់អវិជ្ជមាន</u>*

ចំពោះសកម្មភាពនេះ នឹងអាចប៉ះពាល់ដល់ប្រភេទមច្ឆាជាតិមួយចំនួន ដោយសារ ជំរៅទឹកក្នុងអាងជ្រៅពេក ដែលធ្វើអោយខ្វះអុកស៊ីសែន និងគុណភាពទឹកនៅបាតអាងស្មុយសំបូរដោយឧស្ម័នពុលដល់ជីវិតមច្ឆជាតិ ។ ការរារាំងនៃ ផ្លូវផ្លាស់ប្តូរទីរបស់ត្រី ដោយសារទំនប់ទាំងពីររបស់គំរោង ក៏បណ្តាលអោយមានផល ប៉ះពាល់ដល់ប្រភេទមច្ឆាជាតិ មួយចំនួន។

នៅខ្សែទឹកខាងក្រោមជាប់នឹងកន្លែងបង្ហូរចេញពីទួរប៊ីន ពុំមានមច្ឆជាតិរស់នៅបានទេ ដោយគុណភាពទឹកខ្វះអុកស៊ីសែន និងស្មុយទៀតផង ។

ម្យ៉ាងវិញទៀតអាងស្តុកទឹករបស់គំរោងរ៉ាអគ្គិសនីអាចកើតមានរុក្ខជាតិទឹកសង្រែដូចជា ចក កំប្លោក និងសត្វល្អិតចង្រៃដូចជា អាល់ហ្គ្រី មុស បាក់តេរី ដែលបង្កអោយខ្វះអុកស៊ីសែនរលាយក្នុងទឹក បំពុលគុណភាពទឹកអាង ហើយអាចសំលាប់សត្វ និងរុក្ខជាតិដែលរស់នៅក្នុងទឹកអាងស្លាប់បាន ។

ការបំពុលទឹកដោយសំណល់ រាវ រឹង ពីការិយា ល័យ ផ្ទះបុគ្គលិក ដែលស្នាក់នៅ និងធ្វើប្រតិ បត្តិការ និងថែទាំគំរោង ។

➢ *<u>វិធានការកាត់បន្ថយ</u>*

ក្រុមហ៊ុននឹងធ្វើការគ្រប់គ្រង ការពារ និង ពិនិត្យតាមដាន មិនអោយមានការបំពុលគុណភាពទឹកក្នុងអាងទាំងពីរ ។

ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍ និងសំភារៈ និងអ្នកឯកទេស សំរាប់សំអាតរុក្ខជាតិទឹកសង្រែនិងសត្វល្អិតចង្រៃដែលនឹងអាចកើត មាននៅក្នុងអាងស្តុកទាំងពីរបស់គំរោង។

ការគ្រប់គ្រង និងថែទាំនូវសំណង់សំរាប់អោយត្រីឆ្លងកាត់ពីខ្សែទឹកក្រោមទៅខាងលើបើមានសំណង់បែបនេះ និងតាមដានចរាចរត្រី និងប្រភេទ/ចំនួនរបស់វា ។

ក្រុមហ៊ុននឹងសាងសង់អាងប្រព្រឹត្តិកម្មកាកសំណល់រាវសំរាប់សំអាតទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក ដែលស្នាក់នៅ និងធ្វើប្រតិបត្តិការ និងថែទាំគំរោង ហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះ នឹងមានកំរិតតាម ស្តង់ដានៃការបញ្ចេញចោលសំរាប់ប្រភពការបំពុលដល់ប្រភពទឹកសាធារណៈ ដែលការពារដោយក្រសួងបរិស្ថាន ។

<u>៥.៣.៣.២ ហេតុប៉ះពាល់អវិជ្ជមានទំនោះបរិស្ថានសង្គម និង វិធានការកាត់បន្ថយ</u>

- **<u>ប្រពៃណី វប្បធម៌ និង សាសនា</u>**

➢ *<u>ហេតុប៉ះពាល់អវិជ្ជមាន</u>*

ក្នុងដំណាក់កាលប្រតិបត្តិនិងថែទាំ អាចនឹងប៉ះពាល់ដល់ប្រពៃណី វប្បធម៌ និងជំនឿ សាសនាដែលមានស្រាប់របស់ប្រទេសជាតិកម្ពុជា និងប្រជាពលរដ្ឋនៅក្នុងតំបន់នេះ ដោយសារក្រុមហ៊ុនជ្រើសរើសបុគ្គលិកយកពីតំបន់ឆ្ងាយ ឬជនបរទេស ។

➢ *<u>វិធានការកាត់បន្ថយ</u>*

ក្រុមហ៊ុននឹងរក្សាទំនៀមទំលាប់ប្រពៃណី និង ជំនឿសាសនា ប្រទេសជាតិកម្ពុជា និងរបស់ប្រជាពលរដ្ឋនៅក្នុងនិងជុំវិញទីតាំងគំរោង ។

ធ្វើការផ្សព្វផ្សាយនិងអប់រំណែនាំដល់បុគ្គលិកកម្មករគំរោង អោយយល់ដឹងអំពីការថែរក្សាទំនៀមទំលាប់ប្រពៃណី វប្បធម៌ និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុងតំបន់ទាំងនោះ ។

- **<u>ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត</u>**

➢ *<u>ហេតុប៉ះពាល់អវិជ្ជមាន</u>*

ក្នុងដំណាក់ប្រតិបត្តិការទំនប់រ៉ាអគ្គិសនីកំចាយ នឹង មានផលប៉ះពាល់ដល់ផ្នែកផ្គត់ផ្គង់ទឹកស្អាត ជាពិសេសរដ្ឋាករទឹកក្រុងកំពត ដោយមានការបំពុលគុណភាព ទឹក ។ ព្រោះថាស្ថានីយ៍បូមទឹកចូលទៅ រោងចក្រសំអាតនៅចំងាយប្រហែល ៥០០ម ពីទីតាំងទំនប់ ទីពីរ ហើយទឹកដែលហូរចេញពីផ្ទះជលិតថាមពល តែងតែមានខ្លិនស្អុយ ។

ការបញ្ចោញចោលកាកសំណល់រាវ រឹង ពីការិយាល័យ ពីផ្ទះបុគ្គលិក កម្មករ ទៅលើដី និងក្នុងប្រភពទឹកឈូ ។

ការបំពុលទឹកពីសកម្មភាពកើនឡើងនៃភ្ញៀវ ទេសចរជាតិ និងអន្តរជាតិមកលេងកំសាន្តនៅ តំបន់ទឹកឈូ ។

ការប៉ះពាល់ដល់គុណភាពប្រភពទឹកឈូនេះ ធ្វើអោយ រដ្ឋាករទឹកកំពត មានការចំណាយទុន ច្រើនសំរាប់ សំអាត មុននឹងចែកចាយដលអ្នក ប្រើប្រាស់ ។

➢ *ចិធានការគាត់បន្ថយ*

ក្រុមហ៊ុននឹងធ្វើការពីភក្សាជាមួយរដ្ឋាករទឹក មន្ទីរនិងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្តូរទីតាំងស្ថានីបូមទឹក សំរាប់យកទៅសំអាត ទៅនៅក្នុងទីតាំងអាងទីពីរវិញ ។

ក្រុមហ៊ុននឹងចាត់វិធានការយ៉ាងហ្មឹងមុ័តក្នុងការ គ្រប់គ្រង កាកសំណល់រឹង សំណល់រាវ ដោយសាង សង់បង្គន់អនាម័យ ព្រមទាំងរៀបចំប្រមូល សំណល់រឹង និងសំរាមយកទៅចោល នៅទីតាំង ដែលមានសុវត្ថិភាព ដល់បរិស្ថាន និងសង្គម ។

ក្រុមហ៊ុននឹងជួយពង្រឹងផ្នែកគ្រប់គ្រងអនាម័យក្នុង តំបន់ទឹកឈូ តាមលទ្ធភាពជា បច្ចេកទេស និងជាថវិការ ។

- **ផ្លូវគមនាគមន៍**

➢ *ហេតុប៉ះពាល់អចិជ្ជមាន*

សកម្មភាពប្រតិបត្តិនិងថែទាំគំរោង អាចនឹងបង្កអោយប៉ះពាល់ដល់ការប្រើប្រាស់ផ្លូវគមនាគមន៍របស់ប្រជាពល រដ្ឋ ក្នុងតំបន់ ដូចជា ការបិទផ្លូវចាស់ៗដែលឆ្លងកាត់តំបន់គំរោង និងហាមមិនអោយប្រជាជនចេញចូលឡើងភ្នំកាត់តាម ផ្លូវដែលសាងសង់ដោយគំរោងនៅក្នុងតំបន់ជុំវិញអាងទីមួយនិងអាងទីពីររបស់គំរោងគំរោង ។ល ។

ការកកចង្អៀតលើដងផ្លូវក្នុងតំបន់ទឹកឈូអាចនឹងកើតមាន នៅក្នុងតំណាក់កាលនេះ ដោយមានការប្រព្រឹត្តទៅនៃ ការលក់ដូរជាធម្មតាវិញ និងដោយសារកំនើនភ្ញៀវមកលេងតំបន់នេះ ព្រោះអាចកំសាន្តជាមួយធម្មជាតិផង និងទស្សនា ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងវារីអគ្គិសនីកំចាយនេះផង ។

➢ *ចិធានការគាត់បន្ថយ*

ក្រុមហ៊ុននឹងធ្វើការ សហការជាមួយស្ថាប័នជាប់ទាក់ទង រៀបចំដោះស្រាយ ចំពោះបញ្ហាផ្លូវចុះឡើងទៅតំបន់ភ្នំ ក្បែខាងតំបន់គំរោង សំរាប់ប្រជាពលរដ្ឋទូទៅ ដើម្បីជំនួសទីតាំងផ្លូវចាស់ដែលត្រូវហាមឃាត់ និងគ្រប់គ្រង ដោយគំរោង ។

ក្រុមហ៊ុននឹងដាក់ផ្ទាក់សញ្ញាចរាចរ តាមផ្លូវចេញចូលរបស់គំរោង សញ្ញាហាមឃាត់ សញ្ញាសំរាប់ផ្លូវវាង ដើម្បីសំរួល ចរាចរក្នុងតំបន់គំរោងអោយបានល្អប្រសើរ ។

ក្រុមហ៊ុននឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នទេសចរណ៍ ក្នុងការធ្វើសណ្តាប់ធ្នាប់ ដើម្បីបញ្ជៀសបញ្ហាចរាចរ ក្នុងតំបន់ទឹកឈូនេះ ។

- **សុខភាពសាធារណៈ**

➢ *ហេតុប៉ះពាល់អចិជ្ជមាន*

គំរោងវារីអគ្គិសនីអាចកើតមានរុក្ខជាតិទឹកសង្រៃដូចជា ចក កំបោក និងសត្វល្អិតចង្រៃ ដូចជា អាល់ហ្គៀ មុស បាក់តេរី ឬសត្វល្អិតដែលអាចបង្កជំងឺ និងចំលងជំងឺទៅសត្វ និងមនុស្សបាន ជាពិសេសជំងឺកើតឡើងពីប្រភពទឹក (Waterborn diseases) ។

អាចបង្កអោយមានការប៉ះពាល់ដល់សុខមាលភាព បុគ្គលិកកម្មកររបស់ក្រុមហ៊ុន ដោយសារតំបន់នេះជាតំបន់កើតជំងឺគ្រុនចាញ់ គ្រុនសន្ទុំ ។

ចំពោះដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងនេះដែរ អាចបង្កអោយមានការប៉ះពាល់ដល់សុខមាលភាពរបស់ប្រជាពលរដ្ឋ ក្នុងតំបន់នេះ ដោយសារបុគ្គលិក កម្មកររបស់ក្រុមហ៊ុន ហើយអ្នកទាំងនោះអាចចម្លងជំងឺផ្សេងៗដែលអ្នកភូមិដូចជា ជំងឺអេដស៍ ជំងឺកាមរោគ ជំងឺរបេង ។ល។

➢ *<u>វិធានការកាត់បន្ថយ</u>*

ក្រុមហ៊ុននឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិកកម្មកររបស់ខ្លួនដើម្បីទប់ស្កាត់ជំងឺទាំងនោះកុំអោយកើតមាន និងឆ្លងទៅប្រជាពល រដ្ឋក្នុងតំបន់នោះ ។

ក្រុមហ៊ុននឹងធ្វើការគ្រប់គ្រង ការពារ និង ពិនិត្យតាមដាន មិនអោយមានការបំពុលគុណភាពទឹកក្នុងអាងទាំងពីរ ។

ក្រុមហ៊ុននឹងត្រៀមបំពាក់ឧបករណ៍ និងសំភារៈ និងអ្នកឯកទេស សំរាប់សំអាតរុក្ខជាតិទឹកសង្រៃនិងសត្វល្អិតចង្រៃដែលនឹងអាចកើត មាននៅក្នុងអាងស្តុកទាំងពីរបស់គំរោង ។

ក្រុមហ៊ុននឹងសាងសង់អាងប្រព្រឹត្តិកម្មកាកសំណល់រាវសំរាប់សំអាតទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក ដែលស្ថាក់នៅ និងធ្វើប្រតិបត្តិការ និងថែទាំគំរោង ហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះ នឹងមានភ័ឥតតាម ស្តង់ដានៃការបញ្ចេញចោលសំរាប់ប្រភពការបំពុលដល់ប្រភពទឹកសាធារណៈ ដែលការពារដោយក្រសួងបរិស្ថាន ។

- <u>ហានិភ័យ (Risk)</u>

➢ *<u>មេគុណប៉ះពាល់អតិថិជន</u>*

ក្នុងដំណាក់កាលនេះអាចនឹងមានហានិភ័យដោយសារគ្រោះធម្មជាតិ ការធ្វេសប្រហែសផ្នែកសន្តិសុខ/អំពើភាវរកម្ម ឬសង្គ្រោមផងដែរ ។ ការកើតមានការរញ្ជួយដី ឬបន្ទុះភ្នំភ្លើងនៅក្នុងតំបន់គំរោង ការទទួលរងឥទ្ធិពលពីព្យុះភ្លៀងទីហ្វុង ឬព្យុះផ្សេងទៀត ពីឈូងសមុទ្រថៃ អាចបង្កអោយមានមហន្តរាយធំៗ ដូចជាការបាក់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ជាពិសេសការធ្វើអោយរងរបួស និងស្លាប់បាត់បង់ ជីវិតដល់បុគ្គលិកកម្មករ ព្រមទាំងប្រជាពលរដ្ឋនៅក្នុង/ក្បែរខាងតំបន់គំរោង ។ យោងតាមរបាយការណ៍សិក្សាភូគព្ភសាស្ត្ររបស់គំរោង និងការចុះអង្កេតរបស់ក្រុមសិក្សារបស់សាវ៉ាក់ (SAWAC) យើញថា ភូគព្ភសាស្ត្រក្នុងតំបន់គំរោងពុំមានលក្ខណៈជាសិលាជាប់មាំខ្លាំងឡើយ គឺមានសិលាថ្មកក់មិនស្មើសាច់ ដែលភ្ជាប់ ដោយស៊ីម៉ង់ធម្មជាតិ ពុំសូវជាប់មាំ នៅឆ្ងាស់គ្នាជាមួយស្រទាប់ដីឥដ្ឋល្បាយខ្សាច់ ។ ដូចនេះការសាងសង់ទំនប់វារីអគ្គិសនីកំចាយ អាចនឹងមានការរញ្ជួយដីក្នុង និងក្បែរខាងតំបន់គំរោង ការបាក់ទំនប់ និងបាក់ភ្នំនាថ្ងៃអនាគត ដោយសារទំងន់ និង សំពាចទឹកក្នុងអាងទីមួយដែលមានចំណុះ ៦៨១ លាន ម៉ែត្រគូប

បើសិនជាគ្មានការសិក្សាអោយបាន ឬតំលើភូគព្ភសាស្ត្រដី ថ្ម នៅក្នុងតំបន់គំរោង ជាពិសេស ភូគព្ភសាស្ត្រដី ថ្មត្រង់ទីតាំងទំនប់ និង ជើងផ្ទៃអាងទីមួយ (ទំនប់ធំ និងអាងធំ) ។

ការឆេះព្រៃក្នុងតំបន់ គំរោងដែលបណ្តាលមកពីការធ្វេសប្រហែស ឬអំពើការរកម្ម ក៏អាចបង្កអោយមានមហន្តរាយ /គ្រោះថ្នាក់ធំដល់ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់គំរោង ធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង ។

ការកើតមានសង្គ្រាមឈានពានលើបូរណភាពទឹកដីនៃប្រទេសកម្ពុជា ក៏ជាឧបសគ្គដល់កិច្ចដំណើរការ និងថែទាំគំរោង ជួនកាលសង្គ្រាមអាចបំផ្លាញគំរោងទាំងស្រុងទៀតផង។

➢ *<u>វិធានការគ្រាន់បន្តួយ</u>*

ក្រុមហ៊ុននឹងធ្វើការសិក្សាតាមដានបន្ថែមទៀតនៅក្នុងតំណាលកាលប្រតិបត្តិការ និងថែទាំ លើហេតុការលេច ជ្រាបទឹកចេញពីរអាងធំ និងសញ្ញានានាដែលអាចឈានទៅដល់ការបាក់ទំនប់ និងការបាក់ភ្នំក្នុងតំបន់គំរោងវារីអគ្គិសនីកំចាយនេះ ។

ក្រុមហ៊ុននឹងប្រុងប្រយ័ត្នគ្រប់វិនាទីក្នុងការការពារសន្តិសុខចំពោះគ្រឿងផ្ទុះនានា ការឆេះព្រៃ និងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នមានសមត្ថកិច្ចដើម្បីទប់ស្កាតរាល់អំពើការរកម្មក្នុងតំបន់គំរោង ។

ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់ទំនប់ ការបាក់ភ្នំ ឬការរញ្ជួយដីក្នុងតំបន់គំរោងដល់ប្រជាជនដែលរស់នៅតាមដងស្ទឹងទឹកឈូ និងព្រៃកកំចាយ និងតំបន់ក្បែរខាងគំរោងកំចាយទាំងអស់អោយបានជ្រាបហេតុការណ៍ខាងលើទាន់ពេលវេលាតាមតែអាចធ្វើទៅបានបើសិនជាមានហានិយភ័យបែបនេះកើតឡើង ។

ក្រុមហ៊ុននឹងបង្ហូរទឹកឱ្យអស់ពីអាង នៅពេលមានបញ្ហាគ្រោះថ្នាក់ដោយចៃដន្យ ដូចជា ការរញ្ជួយដី សង្គ្រាម និងកំលាំងរុញច្រានមកលើទំនប់ខ្លាំង ។

ក្រុមហ៊ុននឹងមានរៀបចំបំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះ សំភារៈ និងថវិការ ដើម្បីធានាការដោះស្រាយផលប៉ះពាល់ដែលនឹងអាចកើតពីមហន្តរាយខាងលើនេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាព ។

៥.៣.៤ ដំណាក់កាលបិទគំរោង (Project Closure)

ក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុន Sinohydro នឹងធ្វើឡើងក្រោយពី គំរោងត្រូវបានសាងសង់ និងដំណើរការក្នុងរយៈពេលសរុប ៤៤ឆ្នាំ ។ ដូចនេះសកម្មភាពដំណើរការ និងថែទាំគំរោង នឹងបន្តដោយរាជរដ្ឋាភិបាលកម្ពុជា ។ ហើយសង្ឃឹមថា ក្នុងដំណាក់កាលបិទគំរោងរបស់ក្រុមហ៊ុន Sinohydro ពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ដែលគួរអោយកត់សំគាល់ឡើយ ។

កំណត់ចំហាំនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

តារាងលេខ ១៣: តារាងកំណត់ចំហាំនៃហេតុប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយ

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្លាង	តិច	មធ្យម	ខ្លាំង	
ដំណាក់កាលរៀបចំ និង រចនាគំរោង							
ចលចាលអេកូឡូស៊ី							
បច្ចជាតិ និងសត្វព្រៃ	- តំរោង អភិវឌ្ឍន៍វារិអគ្គិសនីកំចាយអាចនឹងមានផលប៉ះពាល់ ដល់សត្វព្រៃ និងមច្ចជាតិមួយចំនួនដែលបិនអាចចៀសវាងបាន ដូចនេះការចនាបួង់តំរោងត្រូវធ្វើការសិក្សាដាក់បញ្ចូលនូវដំណោះស្រាយ សមស្របសំរាប់ផ្លូវឆ្លងកាត់របស់សត្វព្រៃសំរាប់ អោយត្រីចរាចរចុះឡើងតំបន់ទំនប់បាន ។	- ធ្វើការសិក្សារចនាបួង់តំរោងដោយរួមបញ្ចូលនូវសំណង់សិលប្បៈការសំរាប់អោយត្រីឆ្លង កាត់បាន ។ - ធ្វើការសិក្សា និងមានការសហការជាមួយតំណាងឧទ្យានជាតិបូកគោ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទរកដំណោះស្រាយសំរាប់ផ្លូវសត្វឆ្លងកាត់បាន ។			✓		
បរិស្ថានសង្គម							

ឃនឃានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្នាត	តិច	បឋម	ធ្ងាំង	
ការរស់នៅរបស់សហគមន៍ និងការប្រើប្រាស់ដី	- ដំណាក់កាលនេះគំរោងរាចនឹងបង្កផលប៉ះពាល់ដល់សតិអារម្មណ៍ចំពោះការរស់នៅ និងរករបរចិញ្ចឹមជីវិត របស់ប្រជាពលរដ្ឋនៅតំបន់ទឹកឈូ ដែលពួកគាត់មានការព្រួយបារម្ភ និងភ័យខ្លាចក្រុមហ៊ុនទន្ទ្រានយកដី ដែលពួកគាត់បានកាន់កាប់ស្នាក់នៅ និងធ្វើចំការ ហើយនិងបាត់បង់មុខរបររកស៊ីចិញ្ចឹមជីវិតលក់ដូរអាហារ ផ្លែឈើនៅតំបន់ទេសចរណ៍ទឹកឈូនេះ ។ - អាចនឹងប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋដែលមានរបរប្រមូលអនុផលព្រៃឈើ ដូចជាកាប់ឬស្សី បោចផ្តៅ កាប់អូស រើសផ្លែឈើ ដែលពួកគាត់មានការព្រួយបារម្ភ ខ្លាចក្រុមហ៊ុនឈប់អោយពួកគាត់ឡើងទៅកាប់ឬស្សី កាប់អូស បោចផ្តៅ/រឈ្ម នៅតំបន់កំចាយនេះ ។ - ម្យ៉ាងទៀតប្រជាជនទាំងបីប្រភេទខាងលើព្រួយបារម្ភខ្លាចក្រុមហ៊ុនបិទផ្លូវដែលមានស្រាប់ក្នុងតំបន់ទឹកឈូ និងកំចាយ នេះ មិនអោយចេញចូលបានដូចសព្វដង ។ ព្រោះពួកគាត់ពុំមានពតិមានច្បាស់លាស់អំពីគំរោងវ៉ារីអគ្គិសនីកំចាយ ។	- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងតំបន់គំរោងនូវគោលបំណងអភិវឌ្ឍន៍ និង ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អោយប្រជាជនបានជ្រាប ដូចជាជូនដំណឹងអោយបានដល់អាជ្ញាធ័រភូមិ ឃុំ ការលើកផ្លាកប៉ាន់ណូស្តីអំពីពតិមានគំរោង និងរូបភាពគំរោងអភិវឌ្ឍន៍កំចាយ ។ - ជូនដំណឹងពាក់ព័ន្ធនឹងការកាន់ កាប់ដីរបស់ប្រជាជនដោយ មិនធ្វើអោយប៉ះពាល់ដល់ការកាន់កាប់ដី និង ការប្រកបរបររកស៊ីរបស់ ពួកគេក្នុងតំបន់គំរោង ។ - ធ្វើការពិភាក្សា និងប្រឹក្សាយោបល់ ពីសហគមន៍ក្នុងតំបន់នោះ និងជូនដំណឹង ជាបន្តបន្ទាប់នូវតំរូវការដី សំរាប់ហេដ្ឋាសម្ព័ន្ធគំរោង ព្រមទាំងពេលវេលា នៃការសាងសង់សមាសភាព គំរោងនិមួយៗ ដើម្បីអោយប្រជាពលរដ្ឋក្នុងតំបន់ មានការរៀបចំដំណោះស្រាយ ការរស់នៅ របររកស៊ី និងកម្មសិទ្ធិដីធ្លី ផ្ទះសំបែង ។ល ។			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្លាន	តិច	មធ្យម	ខ្លាំង	
ខ្វះខាតសិទ្ធិប្រើប្រាស់ទឹកស្ទឹងកំចាយ	- មានការបារម្ភពីផ្តែកផ្គត់ផ្គង់ទឹកស្អាត រដ្ឋាករទឹកក្រុងកំពត ខ្លាចមានការខ្វះប្រភពទឹកសំរាប់បូមផ្គត់ផ្គង់ទឹកក្នុងទីក្រុងកំពត និងខ្លាចគំរោងមានការបំពុលគុណភាពទឹក ពេលសាងសង់ពេលដំណើរការ ដែលមានបញ្ហាដល់ការសំអាតទឹកមុននឹងចែកចាយដល់ អ្នកប្រើប្រាស់ ។	- ធ្វើការសិក្សារចនាបួង់គំរោងដែលអាចធានាការបោះទឹកមកខ្សែទឹកខាងក្រោមឱ្យបានគ្រប់គ្រាន់ជាពិសេសនៅរដូវប្រាំង សំរាប់តំរូវការប្រើប្រាស់របស់រដ្ឋាករទឹក និងសហគមន៍រស់នៅតាមដងស្ទឹងទឹកឈូ និងរក្សាអេកូឡូស៊ីរបស់ ស្ទឹងនេះផង ។ - រៀបចំផែនការគ្រប់គ្រង រាល់ការបំពុលទឹកដោយសារសកម្មភាពគំរោង ។ - ធ្វើការផ្សព្វផ្សាយរាល់ការងារដែលអាចបង្កការបំពុលគុណភាពទឹក ដល់រដ្ឋាករទឹក និងអ្នកប្រើប្រាស់ទឹកស្ទឹងទឹកឈូ ព្រែកកំពុងបាយ ទាំងអស់ជ្រាបជាពត៌មានក្នុងរយៈពេលមួយសប្តាហ៍មុនយ៉ាងតិច ។ - អនុញ្ញាតិអោយ រដ្ឋាករទឹកក្រុងកំពតមានទីតាំងស្ថានីយបូមទឹក intake នៅក្នុងអាងទីពីរ ។		✓			
មហាន្តរាយដល់ជីវិតនិងទ្រព្យសម្បត្តិប្រជាជន	- ប្រជាជនដែលរស់នៅតាមដងស្ទឹងទឹកឈូ និងព្រែកកំចាយ មានការបារម្ភ ខ្លាចបាក់ទំនប់ និងបាក់ភ្នំនាថ្ងៃអនាគត ដោយសារគំរោងវារី	- ធ្វើការសិក្សារចនាបួង់គំរោងដែលអាចធានាមិនអោយមានការបាក់ទំនប់ ការបាក់ភ្នំក្នុងតំបន់គំរោងវារីអគ្គិសនីកំចាយនេះ ។			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្លាង	ពិច	មធ្យម	ខ្លាំង	
	អគ្គិសនីនេះ ដែលអាចបំផ្លាញដំណាំទ្រព្យសម្បត្តិ ផ្ទះសំបែង និងអាចសំលាប់ជីវិតសត្វ និងមនុស្សទៀតផង។	- ផ្សព្វផ្សាយរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់ទំនប់ ការបាក់ភ្នំ ឬការរញ្ជួយដីក្នុងតំបន់គំរោងដល់ប្រជាជនដែលរស់នៅតាមដងស្ទឹងទឹកឈូ និងព្រៃកកំចាយ និងតំបន់ក្បែរខាងគំរោងកំចាយទាំងអស់អោយបានជ្រាបជាពត៌មានទូវ ហេតុការណ៍ខាងលើទាន់ពេលវេលាតាមតែអាចធ្វើទៅបាន ។ - រៀបចំបំរុងទុកនូវក្រុមអ្នកជួយសង្គ្រោះ សំភារៈ និងថវិការ ដើម្បីធានាការដោះស្រាយផលប៉ះពាល់ដែលនឹងអាចកើតពីមហន្តរាយខាងលើនេះទាន់សភាពការណ៍ និងមានប្រសិទ្ធិភាព ។					
ដំណាក់កាលសាងសង់គំរោង							
ធនធានរូបសាស្ត្រ							
សណ្ឋានដី និងដានលេខា	- ការប្រែប្រួលសណ្ឋានដីក្នុងទីតាំង គំរោងដោយសារសកម្មភាពឈូសឆាយ និងពង្រាបដីស្រទាប់លើដែលមានតំរបព្រៃឈើនៅតំបន់អាងទីមួយ និងដីចំការដំណាំមួយចំនួននៅតំបន់អាងទីពីរ ។ - ការប្រែប្រួលដានលេខា (ខ្សែកោងកំពស់ដី)	- ធ្វើការឈូសឆាយតែទីតាំងចាំបាច់សំរាប់បំរើអោយការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងកំចាយដែលមានរៀបរាប់ក្នុងរចនាប្លង់លំអិត ។ - ការជ្ជានយកដីក្នុងតំបន់គំរោងត្រូវធ្វើការតែលំអិនលប់ដីតាមស្រទាប់ដែលអាចដាំដុះឡើងវិញបាន		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			គ្មាន	តិច	មធ្យម	ខ្លាំង	
	យ៉ាងខ្លាំង ដោយសារសកម្មភាពពង្រាបដី ក្នុងការធ្វើទំនប់ ផ្លូវថ្នល់ចេញចូលតំបន់គំរោង អាគារផលិតថាមពលអគ្គិសនី កន្លែងសាងសង់ រោគារសំរាប់ ទីស្នាក់ការ និងផ្ទះបុគ្គលិកកម្មការ របស់គំរោង ។	ទៀតផង ។					
ការហូរច្រោះ និងគុណភាពដី	- តំបន់គំរោងកំចាយជាតំបន់ភ្នំ មានចំណោទចោទ ខ្លាំង (I=0 ។៣១) ដូចនេះ សារការឈូសឆាយ ដីដែលមានគំរបព្រៃឈើ នឹងងាយមានការហូរ ច្រោះដី នៅពេលមានភ្លៀងធ្លាក់ និងជាពិសេស រដូវវស្សា ។ - គំរោងអាចនឹងបង្កផលប៉ះពាល់ដល់គុណភាពដី ស្រទាប់លើ Soil Quality ដែលធ្វើអោយ បាត់បង់ ជីរជាតិរបស់ដី បណ្តាលមកពីសកម្មភាព សាងសង់របស់គំរោង ។	- ការឈូសឆាយដី ពង្រាបដី សំរាប់ការសាងសង់ ដោយគោរពតាមលក្ខណៈទំរងប្រភេទដី ដើម្បី ទប់ស្កាត់ ឬបន្ថយការហូរច្រោះដី ដោយសារសកម្ម ភាពសាងសង់របស់គំរោង ។ - ការបង្ហាប់ដីក្នុងតំបន់សាងសង់អោយបានត្រឹមត្រូវ តាមបទដ្ឋានការងារដី ។ - ក្រុមហ៊ុននឹងដាំកំរាលរុក្ខជាតិ ស្មៅ ឬ កូនឈើ តាមជំរៀលជើងទេរក្នុងតំបន់ការដ្ឋានរបស់គំរោង ដើម្បីជួយបន្ថយការហូរច្រោះដី ។			✓		
ប្រព័ន្ធទឹកលើដី (ស្ទឹង ព្រែក និង ទន្លេ)	- ការប្រែប្រួលដល់ប្រព័ន្ធទឹកលើដី និង គុណភាព របស់វា ដោយសារសកម្មភាពសាងសង់របស់ គំរោង ។ - ការសាងសង់ទនប់ទីមួយ និងទំនប់ទីពីរ នឹងមាន	- សាងសង់ផ្លូវទឹកបង្ខៀងការដ្ឋាន ដើម្បីផ្តល់ទឹកមក ខ្សែទឹកខាងក្រោមបានធម្មតា និងបញ្ជៀសការ ខូរកករដី បំពុលគុណភាពទឹក ។ - ការកាប់ឆ្ការព្រៃ ឈូសឆាយដី នឹងត្រូវធ្វើនៅ		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្លាន	ពិច	មធ្យម	ខ្លាំង	
	ដែលប៉ះពាល់ដល់បរិមាណធាទឹកហូររបស់ស្ទឹងទឹកឈូ និងព្រែក កំពង់បាយ ។ - ការកាប់ឆ្ការព្រៃ ឈូសឆាយដី ការបោះចោលសំណល់រឹង សំណល់រាវ លើទីវាលក្បែរប្រភពទឹកពីសំណាក់កម្មករតំរោង ជាពិសេសការលេចធ្លាយនៃប្រេងឥន្ធនៈ និងប្រេងរំអិល ពីគ្រឿងយន្តនានាក្នុងការដ្ឋានសាងសង់ បង្កអោយមានការបំពុល គុណភាពទឹកស្ទឹងកំចាយ និងព្រែកកំពង់បាយ។ ការចុះងូតទឹករបស់កម្មកររាប់រយនាក់ក្នុងស្ទឹង ក៏ជាប្រភពបំពុល ដល់គុណភាពទឹកផងដែរ ។	រដូវប្រាំង ដើម្បីបន្ថយការហូរច្រោះដីខ្លាំង។ - អប់រំដល់បុគ្គលិក កម្មករអំពីការបោះបង់កាកសំណល់រឹង សំណល់រាវ ជាពិសេសការកំពុបប្រេងឥន្ធនៈ ប្រេងរំអិល នៅលើដី ដែលបណ្តាលអោយខូចគុណភាពដីនិងទឹកនៅក្នុងតំបន់តំរោង។ - គ្រប់គ្រង និងការពារសំណល់ រឹង-រាវគ្រប់ប្រភេទ មិនអោយបោះចោលនិងបង្ហូរចូលទៅក្នុងឬក្បែរទឹកស្ទឹង ឬព្រែកឡើយ។ - រៀបចំអោយមានប្រព័ន្ធទឹកស្អាតប្រើប្រាស់ដល់ទីតាំងការដ្ឋាន និងជំរុំ/ផ្ទះកម្មករ គ្រប់គ្រាន់ បង្កលក្ខណៈងាយស្រួលដល់កម្មករក្នុងការ ងូត លាង ជុះ ប្រាណ សំភារៈ និងសំលៀកបំពាក់ ។					
ការរញ្ជួយដី (seismology)	- ការរញ្ជួយដីអាចនឹងបង្កឡើងដោយសារការបំផ្ទុះផ្តាំងថ្ម នៅការដ្ឋានធ្វើទំនប់ ធ្វើផ្លូវចេញចូល និងសំណង់ផ្សេងៗទៀត ។ - ការរញ្ជួយដីពីការបំផ្ទុះនេះអាចនឹងរអិលបាក់ផ្នែកខ្លះនៃកំពូលភ្នំនៅក្នុងតំបន់តំរោង ដែលពុំមានលក្ខណៈជាប់មាំ ។	- ធ្វើការសិក្សាអោយបានត្រឹមត្រូវនូវផលលំបាកនានាដែលនឹងអាចកើតចេញពីការបំផ្ទុះផ្សេងៗ នៃការងារសាងសង់តំរោងវារីអគ្គិសនីកំចាយនេះ ។ - កំណត់ភ័ត្តរញ្ជួយ និងកំលាំងបំផ្ទុះ ដើម្បីបញ្ឈៀសការបាក់រអិលភ្នំ និងដើម្បីកាត់បន្ថយសំលេង រំខានដល់សត្វព្រៃរស់នៅក្នុងតំបន់ឧទ្យានជាតិបូកគោ ។			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
	- ការរញ្ជួយដីពីការបំផ្ទុះនេះអាចបង្កគ្រោះថ្នាក់ដល់សត្វ និងមនុស្សផងដែរ ។	- ផ្តល់ពត៌មាន និងផ្សព្វផ្សាយ ដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាន នូវកាលបរិច្ឆេទ និងពេលវេលាបំផ្ទុះ ។ ដើម្បីការពារសុវត្ថិភាពគ្រោះថ្នាក់ដល់មនុស្ស និងសត្វព្រៃ តំបន់កំចាយ ។ - ការបំផ្ទុះត្រូវធ្វើនៅពេលថ្ងៃ ។					
ការបំពុលខ្យល់	- ដំណាក់កាលសាងសង់នេះ អាចនឹងបំពុលខ្យល់ដោយសារការដុតព្រៃឈើ ដើម្បីសំអាតការដ្ឋាន និងផ្សែងដែលបំភាយចេញ ពីគ្រឿងចក្រសាងសង់ និងរថយន្តដឹកជញ្ជូនសំភារៈ និងការបំផ្ទុះសំរាប់ការងារសាងសង់របស់គំរោង។	- ការដុតបំផ្លាញឈើដែលកាប់ក្នុងផ្ទៃអាងទីមួយ ធ្វើទៅតាមបទដ្ឋានបច្ចេកទេស ដើម្បីការពារការឆេះរាលដាលព្រៃឈើក្បែរខាង ។ - ឈើដែលមានអង្កត់ផ្តឹតចាប់ពី ៣០០មម ឡើងទៅ នោះក្រុមហ៊ុននឹងយកប្រើប្រាស់អោយអស់លទ្ធភាពក្នុងការងារសាងសង់ ហើយធ្វើសហការជាមួយ រដ្ឋបាលព្រៃឈើ និងអ្នកកែច្នៃនិងប្រើប្រាស់ឈើ ដើម្បីលក់បើមានការចាំបាច់។ ធ្វើយ៉ាងនេះ អាចចំណេញប្រាក់ផង និងកាត់បន្ថយការបំពុលបរិយាកាសផង ។ - ប្រើប្រាស់ម៉ាស៊ីន គ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានការបញ្ចេញផ្សែងតិច ដើម្បីកាត់បន្ថយការបំពុលខ្យល់ក្នុងតំបន់នោះ ។			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្នុង	តិច	មធ្យម	ខ្លាំង	
		- ជ្រើសរើសជាតិផ្ទុះដែលមិនបង្កការបំពុលខ្យល់ខ្លាំង ។					
ការបំពុលទឹក	- សកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អាចនឹងបំពុលគុណភាពទឹកស្ទឹងទឹកឈូ ព្រៃកកំពង់បាយ និងអាចបំពុលដល់តំបន់ឆ្នេរពេលដែលមានចរន្តទឹកហូរខ្លាំងពីស្ទឹងទឹកឈូ ។ ការបំពុលគុណភាពអាចបង្កឡើងដោយ (១) ការខួងឬជីកដី និងការបំផ្ទុះថ្ពក់ , (២) កាកសំណល់រឹង កមពីសំណល់សំភារៈសាងសង់ និងសំណល់ មកពីបុគ្គលិក កម្មករក្រុមហ៊ុន , និង (៣) សំណល់រាវ មកពីការហៀរ ឬលេចជាតិប្រេងពីគ្រឿងចក្រ និងរថយន្ត) ។ - ការហូរច្រោះដី ចេញពីការយកចេញនូវតំបរុក្ខជាតិ ដូចជាការ កាប់ព្រៃ ការឈូសឆាយដីក្នុងតំបន់គំរោងទាំងមូល ។	- ការឈូសឆាយទ្រង់ទ្រាយធំ មិនធ្វើនៅរដូវវស្សាទេ ។ - ធ្វើរបាំងការ ពារកករដី កុំអោយសាយភាយចេញឆ្ងាយពីទីតាំងសាងសង់ ។ - ក្រុមហ៊ុននឹងចាត់វិធានការយ៉ាងហ្មឺងម៉ឺតក្នុងការគ្រប់គ្រង កាកសំណល់រឹង សំណល់រាវ ដោយសាងសង់បង្គន់អនាម័យ ព្រមទាំងរៀបចំប្រមូលសំណល់រឹង និងសំរាម យកទៅចោល នៅទីតាំងដែលមានសុវត្ថិភាព ដល់បរិស្ថាន និងសង្គម ។ - សាងសង់អាងប្រព្រឹត្តិកម្មសំអាតទឹកកខ្វក់ពីការិយាល័យ ផ្ទះបុគ្គលិក ដែលស្នាក់នៅ និងធ្វើប្រតិបត្តិការ និងថែទាំតំរោង ហើយទឹកដែលបង្ហូរចេញពីអាងសំអាតនេះ នឹងមានភាពតាមស្តង់ដានៃការបញ្ចេញចោលសំរាប់ប្រភពការបំពុលដល់ប្រភពទឹកសាធារណៈ ដែលការពារដោយក្រសួងបរិស្ថាន ។			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ល្អ	ពិច	មធ្យម	ខ្លាំង	
		- សាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈរួចរាយបានត្រឹមត្រូវតាមបទដ្ឋានសុវត្ថិភាពដល់បរិស្ថាន និងសង្គម ។ - ប្រើប្រាស់ម៉ាស៊ីនគ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលមានគុណភាព លួមិនលេចហូរជាតិ ប្រេង ឬខ្លាញ់មកលើដី និងប្រភពទឹកក្នុងតំបន់គម្រោង ។					
ការបំពុលដី	- ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អាចនឹងមានការបំពុលដី ដោយសារការកំពុបនៃប្រេងឥន្ធនៈដែលប្រើសំរាប់គ្រឿងចក្រ និងរថយន្តទាំងនោះទៅលើដី ព្រមទាំងការចោលសំណល់សំភារៈសំណង់ដែលមានជាតិពុលលើដី ។ - ការកំពុបលើដីនូវសារធាតុផ្ទុះ ដែលប្រើប្រាស់សំរាប់បំផ្ទុះថ្ម ក៏បង្កការបំពុលដីបានដែរ ។ សំណល់ប្រេង ខ្លាញ់ ជាតិពុលផ្សេងៗរំសេវផ្ទុះអាចបំពុលដីនៅក្នុងការដ្ឋានផ្ទាល់ផង និងនៅតំបន់ក្បែរខាងដោយសារទឹកហូរនាំទៅដល់ផងដែរ ។	- សាងសង់កន្លែងផ្ទុកប្រេងឥន្ធនៈអោយបានត្រឹមត្រូវ មិនអោយកំពុបលើដីទេ ។ - ចាត់វិធានការយ៉ាងតឹងរឹង មិនអោយចាក់ប្រេងម៉ាស៊ីនចាស់ៗ (ប្រេងបាត) ចោលទៅលើដី ព្រមទាំងប្រើ ប្រាស់កែច្នៃទៅជាគ្រឿងចំហេះផ្សេងទៀត ។ - ចាត់វិធានការយ៉ាងហ្មឺងម៉ាត់ក្នុងការគ្រប់គ្រង កាកសំណល់រឹង សំណល់រាវ ដែលសេសសល់ពីការដ្ឋានសាងសង់ និងរៀបចំប្រមូលសំណល់រឹង និងសំរាមយកទៅចោលនៅទីតាំងដែលមានសុវត្ថិភាពដល់បរិស្ថាន និងសង្គម ។		✓			
សំលេង និង រញ្ជួយ	- សកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អាចនឹងធ្វើអោយរំខានដល់ការរស់នៅ	- ប្រើប្រាស់គ្រឿងយន្ត និងមធ្យោបាយដឹកជញ្ជូនដែលមានសំលេងតិច ។		✓			

បរិយាយបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្លាន	ពិច	បច្ចុម	ខ្លាំង	
	របស់ប្រជាពលរដ្ឋ ភ្ញៀវទេសចរណ៍ និងពពួកសត្វព្រៃ ដែលមាននៅក្នុង និងជុំវិញទីតាំងគំរោង ដោយសារមានសំលេងខ្លាំងពីគ្រឿងចក្រ រថយន្ត ម៉ាស៊ីនគ្រប់ប្រភេទពេលកំពុងធ្វើការងារការបំផុះថ្ម ការកាប់រំលំដើមឈើធំៗ ។ល។	- ប្រើប្រាស់គ្រឿងផុំះក្នុងកិរិតសមស្របទៅនឹងបរិស្ថានរបស់តំបន់ឧទ្យានជាតិ ដែលជាជំរកសត្វព្រៃរស់នៅ និងតំបន់ទេសចរណ៍ធម្មជាតិ ។ - កំណត់ពេលវេលាធ្វើការតែពេលថ្ងៃប៉ុណ្ណោះដោយមិនធ្វើការរំខានដល់ប្រជាពលរដ្ឋ ភ្ញៀវទេសចរណ៍ និងសត្វព្រៃក្នុងតំបន់គំរោង ។					
ឥទ្ធិពលរសេរភូម្សាស្ត្រ							
មច្ចជាតិ	- ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គំរោងនេះអាចនឹងធ្វើអោយប្រែប្រួលបរិមាណធាទឹក និងគុណភាពទឹកស្ទឹងកំចាយ និងព្រែក កំពង់បាយ ដោយសារសកម្មភាពសាងសង់ ។ ការបង្ហាំងទឹក ការហូរច្រោះដី និងការចោលសំណល់ · រឹង-រាវលើទីវាល និងក្បែរមាត់ស្ទឹង ជាហេតុធ្វើអោយប៉ះពាល់តិចតួចដល់ធនធានត្រីទឹកសាប និងទឹកភ្ញៀវក្នុងតំបន់នេះ ។ ការរារាំងនៃផ្លូវផ្លាស់ប្តូរទីរបស់ត្រី ដោយសារទំនប់ទាំងពីររបស់គំរោងក៏បណ្តាលអោយមានផល ប៉ះពាល់ដល់ប្រភេទមច្ចាជាតិ មួយចំនួន ។	- សាងសង់ផ្លូវទឹកបង្វៀងការដ្ឋានទំនប់ ដើម្បីមានផ្លូវទឹកសំរាប់ត្រីធ្វើដំណើរចុះឡើងបាន និងផ្តល់ទឹកមកខ្សែទឹកខាងក្រោមបានធម្មតា ព្រមទាំងបញ្ឈៀសការខូរកករដីបំពុលគុណភាពទឹកស្ទឹង និងទឹកព្រែកក្នុងតំបន់គំរោង ។ - សាងសង់សំណង់សិលប្បៈការ សំរាប់រោយត្រីឆ្លងកាត់បាន តាមការចនាប្លង់ត្រឹមត្រូវ ។ - អប់រំដល់បុគ្គលិក កម្មករអំពីការបោះបង់កាកសំណល់រឹង សំណល់រាវ ជាពិសេសការកំពុបប្រែងឥន្ធនៈ ប្រេងរំអិល នៅលើដី និងក្នុងទឹកនៅក្នុងតំបន់គំរោង ។		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	អំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	ពិច	បច្យម	ខ្ទាំង	
		- គ្រប់គ្រង និងការពារសំណល់ រឹង-រាវគ្រប់ប្រភេទ ដោយសាសង់អាងប្រព្រឹត្តកម្ម និងរៀបចំប្រមូលសំណល់រឹង និងសំរាមយកទៅ ចោលនៅទីតាំងដែលមានសុវត្ថិភាពដល់បរិស្ថាន និងសង្គម ។					
ធនធានព្រៃឈើ និងជំរកសត្វព្រៃ	- ដោយតំបន់គំរោងកំចាយស្ថិតនៅក្នុងឧទ្យានជាតិបូកគោ ដែលគ្របដណ្តប់ដោយព្រៃឈើពីរប្រភេទគឺ ព្រៃស្រោង និងព្រៃល្បាយបូស្សីដូចនេះព្រៃឈើទាំងពីរប្រភេទខាងលើក្នុងអាងទីមួយរបស់គំរោងនឹងត្រូវលិចបាត់បង់ ទាំងស្រុងដែលក្នុងនោះមានព្រៃស្រោងចំនួន ១៤១៧ ហ.ត និងព្រៃល្បាយបូក្សីចំនួន ១៤០ ហ.ត ។ - ការបាតបង់ព្រៃក្នុងអាងវារីអគិសនីនេះ បង្ក អោយមានផលប៉ះពាល់អវិជ្ជមានខ្លាំងបង្ហូរដល់ ធនធានព្រៃឈើនៃឧទ្យានជាតិបូកគោ និងនាំទៅដល់ការបាត់បង់ ជំរកសត្វព្រៃក្នុងតំបន់នេះ ដែលជាការព្រួយបារម្ភ និង សោកស្តាយរបស់ប្រជាជន និងរាជរដ្ឋាភិបាលចំពោះសម្បត្តិបរិស្ថានធម្មជាតិរ់បស់មាតុភូមិកម្ពុជា ។	- ក្រុមហ៊ុននឹងធានាមិនកាប់ព្រៃឈើនៅក្រៅពីទីតាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលមានបង្ហាញនៅក្នុងបួង់រចនា គំរោងលំអិត ។ - ធ្វើការពិភាក្សាជាមួយផ្នែកឧទ្យានជាតិ ដើម្បីរកទីតាំងសមស្របក្នុងតំបន់ក្បែរខាងព្រៃដែលបាត់បង់ដោយសារសកម្មភាពគំរោង សំរាប់ដាំឈើ ដាំបូស្សី ទុកជាជំរកដល់សត្វព្រៃផង និងដើម្បីរក្សាលំនឹងអេកូឡូស៊ីបរិស្ថាន ក្នុងឧទ្យានជាតិទាំងមូលផង ។ - ធ្វើការសហការជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថានដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអិវជ្ជមាន ដែលនឹងកើតមានឡើងជាយថាហេតុលើព្រៃឈើដែលនៅជាប់នឹងតំបន់គំរោង ក្នុងដំណាក់កាលនៃការសាងសង់នេះ ។			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ល្អ	ពិត	មធ្យម	ខ្លាំង	
ជីវសាស្ត្រ សត្វព្រៃ	- តំបន់តំរោងនេះមានសត្វព្រៃជាច្រើនប្រភេទ ដែលរស់នៅ ហើយប្រភេទសត្វមួយចំនួនកំពង់ត្រូវបានធ្វើការអភិរក្សដូចជា ខ្លាធំ ជ្រី ខ្លាឃ្មុំ ទោចជាដើម ។ ដូចនេះដោយ សារសកម្មភាពសាងសង់ទំនប់វារីអគ្គិសនី អាងស្តុកទឹក និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត នឹងមានការផ្លាស់ប្តូរទីជំរក ឬថយចុះសត្វព្រៃមួយចំនួន ដែលមាននៅក្នុងតំបន់តំរោង ។ - កាប់ឆ្ការគំរបព្រៃឈើ ការលូសរាយដី ការបំផ្ទុះថ្ម ការដឹកជញ្ជូនសំភារៈសាងសង់ នឹងនាំអោយមានការភ័យខ្លាចដល់សត្វព្រៃទាំងនោះ ដោយសារមានសំលេងរំខានខ្លាំងៗ ចេញពីម៉ាស៊ីនគ្រឿងយន្ត និងគ្រឿង ផ្ទុះទាំងនោះ ។ - ការជ្រើសរើសនូវបុគ្គលិកកម្មករជាប់រយនាក់ចូលមកធ្វើការនៅតំបន់នេះ សំរាប់ការសាងសង់តំរោង នឹងអាចមានសកម្មភាពបរបាញ់ ឬ ចាប់សត្វព្រៃពីសំណាក់បុគ្គលិកកម្មករតំរោងទាំងនោះ នឹងអាច កើតមានផងដែរ ។	- កំណត់ពេលវេលាធ្វើការតែពេលថ្ងៃសំរាប់ការងារទាំងឡាយណាដែលបង្កសំលេង និងរំញ័រ ដើម្បីកុំអោយមានការរំខាន ឬផ្តើលសត្វព្រៃក្នុងតំបន់តំរោងនិងតំបន់ក្បែរខាង ។ - កំណត់ការិតរញួយ និងកំលាំងបំផ្ទុះ និង ប្រើប្រាស់ម៉ាស៊ីនដែលមានសំលេង និងរំញ័រតិច ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃទាំងនេះ ។ - អប់រំ និងដាក់វិន័យដល់បុគ្គលិកកម្មករតំរោង មិនអោយធ្វើការចាប់ឬបរ បាញ់សត្វព្រៃនិងធ្វើចរាចរណ៍សត្វព្រៃនៅក្នុងតំបន់នេះឡើយ ។		✓			

ឧទ្យានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ល្អ	ពិច	បច្ចុម	ខ្លាំង	
តំបន់ឧទ្យានជាតិបូកគោ	- នៅក្នុងដំណាក់កាលសាងសង់គំរោងនេះ អាចនឹងធ្វើអោយប៉ះពាល់ដល់ឧទ្យានជាតិបូកគោ ដោយសារតំបន់គំរោងស្ថិតនៅក្នុងទឹកដី នៃឧទ្យាននេះទាំងស្រុង។ ដូចនេះដោយសារសកម្មភាពសាងសង់គំរោងនឹងបង្កអោយមានផលប៉ះពាល់ដល់អេកូឡូស៊ីរបស់ឧទ្យាន ដូចជាការ កាប់ឆ្ការព្រៃឈើ ការឈូសឆាយដី សំលេងពីគ្រឿងចក្រ ភាពខ្ជៀវខ្ជាំនៃក្រុមកម្មករ ការបំពុលខ្យល់ ប្រភពទឹកដោយសំណល់បញ្ចេញចោលពី ការងារសាងសង់ និងចេញពីមនុស្ស ព្រទាំងការទន្ទ្រានចូលក្នុងព្រៃនៃក្រុមកម្មករ ក្រោយពីការងារ ដើម្បីរកអនុផលព្រៃឈើ ឬចាប់សត្វជាដើម។ - ម្យ៉ាងវិញទៀតទទឹមភ្នាំនៃការងារសាងសង់របស់គំរោងអាចនឹងមានការទន្ទ្រានកាន់កាប់យកដីព្រៃដីឧទ្យានជាតិដែល នៅក្បែរខាងតំបន់គំរោង ពីសំណាក់ជនឈ្មួញតឱកាស ដែលបង្កអោយមានការធ្លាក់ចុះបរិស្ថានក្នុងតំបន់ឧទ្យានជាតិបូកគោ ថែមទៀត ។	- កំណត់ពេលវេលាធ្វើការតែពេលថ្ងៃ សំរាប់ការងារទាំងឡាយណាដែលបង្កសំលេង និងរំញ័រ ដើម្បីកុំអោយមានការរំខាន ឬផ្តើលសត្វព្រៃក្នុងតំបន់គំរោងនិងតំបន់ក្បែរខាង។ - កំណត់ការិតរញួយ និងកំលាំងបំផ្ទុះ និង ប្រើប្រាស់ម៉ាស៊ីនដែលមានសំលេង និងរំញ័រតិច ដើម្បីកាត់បន្ថយការរំខានដល់ពពួកសត្វព្រៃ ។ - សាងសង់អាង បង្គន់អានាម័យសំរាប់អ្នកធ្វើការទាំងអស់នៅក្នុងការដ្ឋាន និងជំរុំស្នាក់នៅរបស់គំរោង ។ រៀបចំប្រពន្ធ័ប្រមូលសំណល់រឹង និងសំរាម យកទៅចោលនៅទីតាំងដែលមានសុវត្ថិភាពដល់បរិស្ថាន និងសង្គម ជាពិសេស មិនអោយប៉ះពាល់ដល់បរិស្ថានរបស់ឧទ្យានជាតិឡើយ។ - ធ្វើការអប់រំនិងដាក់វិន័យដល់កម្មករគំរោង មិនអោយធ្វើការទន្ទ្រានព្រៃក្នុងតំបន់ឧទ្យាន ដើម្បីចាប់ឬបរ បាញ់សត្វព្រៃ ។ - សហការជាមួយតំណាងឧទ្យានុរក្ស ក្រសួងបរិស្ថាន ក្រសួងដែនដីនគរូបនីយកម្មនិងសំណង់			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ល្អ	ពិច	មធ្យម	ខ្លាំង	
		និងស្ថាប័នជាប់ទាក់ទងដទៃទៀត ការពារ និងទប់ស្កាត់កុំអោយមានការរំលោភកាន់កាប់ដីព្រៃនៅក្នុង និងក្បែរខាងតំបន់គំរោង ។					
បរិស្ថានសង្គម / សេដ្ឋកិច្ច							
ការប្រើប្រាស់ដី និងការតាំងលំនៅដ្ឋានឡើងវិញ	- គំរោងអាចនឹងប៉ះ ពាល់ដល់ការប្រើប្រាស់កាន់កាប់ដីរបស់ប្រជាពលរដ្ឋក្នុងតំបន់ទីកឈូ សំរាប់ការសាងសង់ទំនប់ទីពីរ ការិយាល័យ រោងជាង ផ្ទះស្នាក់នៅរបស់បុគ្គលិកកម្មករ និងការសាងសង់ផ្លូវចេញចូលក្នុងតំបន់គំរោង ។ នៅផ្នែកខាងស្តាំស្ទឹងមានដីចំការចំនួន ១៩ម្នាស់ ដែលមានផ្ទៃដីរងផលប៉ះពាល់ ផ្តាល់ប្រមាណ ៥០ហ.ត ដោយសារចនាសម្ព័ន្ធ តំបន់ទំនប់ទីពីរ។ នៅផ្នែកខាងឆ្វេងស្ទឹងនៅក្នុងទឹកដីភូមិមាត់ពាម មានដីចំការចំនួន ១៣ម្នាស់ដី ដែលនឹងត្រូវប៉ះពាល់ដោយការសាងសង់ផ្លូវ ចេញចូលរបស់គំរោងឆ្លងកាត់ចំការរបស់ពូកគាត់ យោងតាមប្លង់ប្បើបចំគំរោងរបស់ក្រុមហ៊ុន ។ - មានកម្មករចំនួន៣៨គ្រួសារ ដែលកំពុងធ្វើ	- ដំណោះស្រាយចំពោះដីចំការ លំនៅដ្ឋានដែលនឹងត្រូវប៉ះពាល់ដោយការងារសាងសង់គំរោងនេះជាបន្ទុករបស់ក្រុមហ៊ុន និងរាជរដ្ឋាភិបាលកម្ពុជា ។ មិនទន្ទ្រានយកដីរបស់ប្រជាពលរដ្ឋដែលបានកាន់កាប់ ដោយសន្តិវិធី (យោងតាមច្បាប់ភូមិ បាលមាត្រាលេខ ៣, ៥, ៨, ២៣, ២៥ និង ៣០) ឡើយដូចជា : ដីភូមិ ដីចំការ និងដីសហគមន៍ ។ - ក្រុមហ៊ុននឹងចូលរួមសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់ អាជ្ញាធរមូលដ្ឋាន និង អនុវត្តទៅតាមការសំរេចចិត្តរបស់ រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលនូវទំនាស់ដីធ្លីទាំងឡាយ ដែលកើតមានដោយសារសកម្មភាពគំរោង ។ - ការទូទាត់ដល់ការបាត់បង់ដីប្រើប្រាស់ខូចខាតលំនៅដ្ឋាន/ផ្ទះយាមចំការ			✓		

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ល្អ	ពិច	មធ្យម	ខ្លាំង	
	ចំការនិងរស់នៅលើដីទាំង១៩ម្ចាស់នេះ ហើយដែលពួកគេនឹងប្រឈមនឹងការបាត់បង់ការងារ និងជំរករស់នៅរបស់គាត់ ។	ដំណាំគ្រប់ប្រភេទ ត្រូវធ្វើការដោះស្រាយ តាមបទដ្ឋាន និងការវាយតំលៃជាក់ស្តែងរបស់គណៈកម្មាការរៀបចំការតាំងលំនៅដ្ឋានឡើងវិញរបស់រាជរដ្ឋាភិបាលកម្ពុជា។ - ក្រុមហ៊ុននឹងខិតខំស្រូបយកកំលាំងពលកម្មពីប្រជាជនដែលបាត់បង់ការងារធ្វើចំការ និងរបររកស៊ីក្នុងតំបន់ទីកឈូនេះ អោយបានច្រើនតាមលទ្ធិភាពដែលអាចធ្វើបាន ។					
ការរស់នៅ និងមុខរបររបស់សហគមន៍មូលដ្ឋាន	- ដំណាក់កាលសាងសង់តំរោងនេះ នឹងអាចមានការប៉ះពាល់ដល់មុខរបររបស់ប្រជាពលរដ្ឋមានរបរចិញ្ចឹមជីវិតក្នុងតំបន់តំរោង ដូចជា អ្នកលក់ដូរនៅរមណីដ្ឋានទីកឈូ អ្នកកាប់ឫស្សី/ផ្តៅ/អូស និងអ្នករកអនុផលព្រៃឈើដទៃទៀត ដោយសារក្រុមហ៊ុន បិទផ្លូវ ឬហាមមិនអោយចូលទៅប្រកបរបរដូចមុនទៀត ឬហាមឃាត់ប្រជាពលរដ្ឋមិនអោយចូលក្នុងតំបន់ ដែលខ្លួនកាន់កាប់សំរាប់ការងារសាងសង់តំរោង ។ - បន្ថែមពីលើនេះទៀត នឹងមានផលប៉ះពាល់ដល់	- ក្រុមហ៊ុននឹងសហការជាមួយឧទ្យានជាតិ និងក្រសួងទាក់ទង ដែលដំណាងអោយរាជរដ្ឋាភិបាលធ្វើការដោះស្រាយរកទីព្រៃឫស្សីក្រៅទីតាំងតំរោង ឬធ្វើការដាំព្រៃឈើនិងឫស្សីនៅតំបន់ក្បែរខាងនៃឧទ្យានបូកគោដើម្បីរក្សាតុល្យភាពបរិស្ថាន ក្នុងតំបន់ផង និងជាធនធានសំរាប់ប្រជាពលរដ្ឋបន្តរបរចិញ្ចឹមជីវិត ដូចពេលដែលមិនទាន់មានការសាងសង់តំរោង។ - ធ្វើសហការជាមួយមន្ទីរទេសចរណ៍រកដំណោះស្រាយដើម្បីរក្សាទុកទីតាំងលក់ដូរនៅទីកឈូ ឬ		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	ពិច	មធ្យម	ខ្លាំង	
	ការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះ ដោយពួកគាត់មានការភ័យខ្លាច និងមិនសូវចូលចិត្តរស់នៅជាមួយអ្នកចំណូលថ្មី បុគ្គលិកកម្មករគំរោងមកពីតំបន់ផ្សេងៗ និងជនជាតិផ្សេងដែលមានប្រពៃណីផ្សេង នឹងអាចកើតមានអំពើមិនសមស្របនឹងច្បាប់រដ្ឋ និងរបៀបរស់នៅរបស់សហគមន៍ ។	រកទីតាំង សមស្របនៅក្បែរទីតាំងចាស់ អោយអ្នកលក់ដូរទាំងនេះបន្តអាជីវកម្មដូចពេលមុន ។ - ក្រុមហ៊ុននឹងខិតខំស្រូបយកកំលាំងពលកម្មពីប្រជាជនដែលបាត់បង់ការងារធ្វើចំការនិងរបររកស៊ីក្នុងតំបន់ទឹកឈូនេះ អោយបានច្រើនតាមលទ្ធិភាពដែលអាចធ្វើបាន ។ - ក្រុមហ៊ុននឹងគោរពតាមទំនៀមទំលាប់ ប្រពៃណីនៃការរស់នៅរបស់ប្រជាពលរដ្ឋ ។ ធ្វើការ អប់រំ-ណែនាំបុគ្គលិក កម្មកររបស់ខ្លួន និងដាក់វិន័យតឹងរឹងបំផុត មិនអោយប្រព្រឹត្តិអំពើល្មើសនឹងច្បាប់រដ្ឋ និងទំលាប់ប្រពៃណីមូលដ្ឋានរបស់ប្រទេសជាតិ និងសហគមន៍នៅក្នុងតំបន់នោះឡើយ ។ - សហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នមានសមត្ថកិច្ច ដើម្បីការពារឬកាត់បន្ថយអំពើទាំងនេះអោយបានលទ្ធផលល្អប្រសើរ ។					
ប្រពៃណី វប្បធម៌ និងសាសនា	- ក្នុងដំណាក់កាលសាងសង់ ក្រុមហ៊ុននាំបុគ្គលិក កម្មករមកពីតំបន់ផ្សេងៗ កមធ្វើការអោយគំ	- ក្រុមហ៊ុននឹងរក្សាទំនៀមទំលាប់ប្រពៃណី និងជំនឿសាសនារបស់ប្រទេសកម្ពុជា និងរបស់ប្រជា		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	អំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ក្នុង	ពិច	មធ្យម	ខ្លាំង	
	រោង ដូចនេះអាចមានផលប៉ះពាល់ដល់ ប្រពៃណីវប្បធម៌ និងជំនឿសាសនា និងទំលាប់ មូលដ្ឋានដែលមានស្រាប់របស់ប្រជាពលរដ្ឋ។ - ម្យ៉ាងវិញទៀតការសាងសង់អាចប៉ះពាល់ដល់កន្លែងសការៈបូជាទាំងឡាយដូចជា ព្រៃ ឬទីទួលអ្នកតា អារក្ស សំណាក់ម្ចាស់ទឹកដីក្នុងតំបន់។	ពលរដ្ឋនៅក្នុង និងជុំវិញទីតាំងគំរោង។ - ក្រុមហ៊ុនអភិរក្សការពារព្រៃអ្នកតា ទីទួល/កន្លែងសការៈបូជាទាំងឡាយ ដែលមាននៅក្នុង និងក្បែរតំបន់គំរោង ។ - ធ្វើការផ្សព្វផ្សាយ និងអប់រំណែនាំដល់ បុគ្គលិកកម្មករគំរោង មិនអោយមានការខុសឆ្គង ឡើយ ។					
ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត	- ក្នុងដំណាក់កាលសាងសង់ទំនប់ការីអគ្គិសនីកំចាយនឹងមានផលប៉ះពាល់ដល់ផ្នែកផ្គត់ផ្គង់ទឹកស្អាតជាពិសេសរដ្ឋាករទឹកក្រុងកំពត ដោយមានការបំពុលគុណភាពទឹកដោយសកម្មភាពសាងសង់ ។ ព្រោះថាស្ថានីយ៍បូមទឹកចូលទៅ រោងចក្រសំអាតនៅចំងាយប្រហែល ៥០០ម ពីទីតាំងទំនប់ទីពីរ ។ ការប៉ះពាល់ដល់គុណភាពប្រភពទឹកឈូនេះធ្វើអោយរដ្ឋាករទឹកកំពត មានការចំណាយទុនច្រើនសំរាប់សំរាត មុននឹងចែកចាយដល់អ្នកប្រើប្រាស់ ។	- អនុវត្តវិធីសាស្ត្របច្ចេកទេស និងប្រើប្រាស់ឧបករណ៍ សំភារៈ ដើម្បីកាត់បន្ថយការបំពុលគុណភាពទឹកស្ទឹងកំចាយ ពីសកម្មភាព សាងសង់គំរោង។ - ធ្វើការជូនដំណឹងច្បាស់លាស់អំពី ថ្ងៃ ខែ និងពេលវេលា ដល់រដ្ឋាករទឹកកំពត និង អ្នកប្រើប្រាស់ប្រភពទឹកឈូទាំងអស់ អំពីការងារសាងសង់ដែលអាចបង្ក អោយមានការបំពុល គុណភាពទឹកស្ទឹងកំចាយនេះ។ - ក្រុមហ៊ុននឹងអនុញ្ញាតិអោយ រដ្ឋាករទឹកក្រុងកំពត មានទីតាំង ស្ថានីយបូមទឹក intake នៅក្នុងអាងទីពីរ ។			✓		
រមណីយដ្ឋាន/ទឹកឆ្នែងកំ	- ការរំខានដល់សកម្មភាពទេសចរណ៍នៅក្នុងតំបន់	- ធ្វើការដោះស្រាយសំរួលចរាចរក្នុងតំបន់ទឹកឈូ		✓			

ធនធានបរិស្ថាន	ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន	វិធានការកាត់បន្ថយ	កំណត់ហេតុប៉ះពាល់បរិស្ថាន				ផ្សេងៗ
			ត្មាន	តិច	មធ្យម	ខ្លាំង	
